# ភាវនាមយៈ

# បុណ្យកើតអំពីការចម្រើនភាវនា

# ភាគទី ៣




រៀបរៀងដោយ

ខ្ញុំព្រះករុណាអាត្មាភាព **ភិក្ខុសីលប្បញ្ញោ ឆៃ សុផល្លី**

**វត្តនិគ្រោធវ័ន គល់ទទឹង**

ព.ស.២៥៥៧

ឈ្មោះសៀវភៅ **ភាវនាមយៈ**

រៀបរៀងដោយ **ភិក្ខុសីលប្បញ្ញោ ផៃ សុផល្វី**

បោះផ្សាយ លើកទី ១

កាលបរិច្ឆេទ ព.ស. ២៥៥៧

ទីកន្លែងធ្វើ វត្តនិគ្រោធវ័នគល់ទទឹងភូមិកោះក្របី សង្កាត់ព្រែកថ្មី ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ

# **អារម្ភកថា**

*ព្រះអង្គទ្រង់ត្រាស់អំពី សេចក្តីព្យាយាម ៤ យ៉ាងគឺៈ*

***១-សំវរបធាន*** *ព្យាយាមប្រយ័ត្ន មិនឱ្យបាបកើតឡើងក្នុងសន្តាន គឺព្យាយាមអប់រំទូន្មានចិត្តកុំឱ្យអកុសលកើតឡើង ។*

***២-បហានបធាន*** *ព្យាយាមលះបាបដែលកើតឡើងហើយ គឺអំពើមិនល្អដែលមានក្នុងសន្តានចិត្ត ត្រូវព្យាយាមលះបង់ចោល ។*

***៣-ភាវនាបធាន*** *ព្យាយាមញុំាងកុសលឱ្យកើតឡើងក្នុងសន្តាន គឺការខិតខំកសាងនូវសេចក្តីល្អ អំពើល្អជានិច្ច ។*

***៤-អនុរក្ខនាបធាន*** *ព្យាយាមរក្សាកុសលដែលកើតឡើងហើយ មិនឱ្យសាបសូន្យទៅវិញ គឺព្យាយាមរលឹករឿយៗនូវកុសលធម៌ដែលមានហើយ ។*

*បុណ្យបានមកដោយការទូន្មានអប់រំ អត់ធ្មត់ សង្កត់ចិត្តឱ្យស្ងប់ បានដល់ការចម្រើនសតិប្បដ្ឋាន សមាធិ វិបស្សនា ដើម្បីធ្វើឱ្យចិត្តឋិតនៅនឹងធឹង ស្ងប់រម្ងាប់ បរិសុទ្ធស្អាតចាកបាបអកុសលពាល់ទង្វើអាក្រក់ផ្សេងៗ ដែលនាំឱ្យចិត្តកករល្អក់ សៅហ្មង ឯទង្វើអាក្រក់ដែលធ្វើឱ្យចិត្ត មិនស្ងប់នោះមាន ៣ យ៉ាងគឺៈ*

***១-អភិជ្ឈា*** *គិតសំឡឹងរំពៃ លួច ឆក់ ប្លន់ ចង់បានទ្រព្យសម្បត្តិអ្នកដទៃ ។*

***២-ព្យាបាទ*** *ការខឹងក្រោធ ប្រណៅនឈ្នានីស គំនុំគុំគួនចង់អាឃាត ព្យាបាទអ្នកដទៃ ។*

***៣-មិច្ឆាទិដ្ឋិ*** *ការយល់ខុសចាកពីហេតុផលពិត ជាក់ស្តែង*

ដូចយល់ឃើញថាឪពុកម្ដាយមិនមានគុណគ្មានបុណ្យ គ្មានបាប គ្មានជាតិមុន គ្មានជាតិក្រោយជាដើម ។

ការអប់រំទូន្មានគ្រប់សង្កត់ចិត្តនេះ គឺសំខាន់ខ្លាំងណាស់ ដែលអាចធ្វើអ្វីផ្សេងៗ ឬពោលស្ដីនិយាយអ្វីបានក៏ដោយសាចិត្ត ជាអ្នកបង្គាប់បញ្ជាមក ទើបធ្វើ ឬនិយាយស្ដីទៅកើត បើចិត្តគិតរឿងអាក្រក់ហើយ ទោះធ្វើទង្វើអ្វីក៏ដោយ ពោលនិយាយស្ដីអ្វីក៏ដោយ ក៏សុទ្ធតែអាក្រក់ទៅតាមចិត្តនោះទាំងអស់អ៊ីចឹងដែរ តែបើចិត្តគិតរឿងល្អ រឿងបុណ្យកុសល ទោះធ្វើអ្វីក្ដី និយាយស្ដីអ្វីក្ដី ក៏សុទ្ធតែល្អ ជាបុណ្យកុសលទាំងអស់ដែរ ដូច្នេះត្រូវខំប្រឹងប្រែងព្យាយាមទូន្មានអប់រំគ្រប់សង្កត់ចិត្ត គឺធ្វើឱ្យចិត្តគិតតែរឿងល្អៗតែម្យ៉ាងប៉ុណ្ណោះ មួយវិញទៀត ការអប់រំទូន្មាន គ្រប់សង្កត់ចិត្តនេះទៀតសោតក៏ជាចំណុចសំខាន់បំផុត នៅក្នុងព្រះពុទ្ធសាសនាផងដែរ ដែលអាចជួយឱ្យបានទៅដល់គោលដៅចុងក្រោយ នោះគឺជាព្រះនិព្វាន ។

សៀវភៅ **ភាវនាមយៈ**នេះ ខ្ញុំសង្ឃឹមថា នឹងបានជាផ្លូវ ចង្អុលបង្ហាញអំពីអានិសង្សខ្លះៗ នៃការធ្វើបុណ្យរបស់ពុទ្ធបរិស័ទទាំងឡាយ ដែលកើតអំពីការចម្រើនភាវនា អប់រំ ទូន្មានចិត្ត ។

**សូមអនុមោទនា** !!!

ថ្ងៃ ៨រោច ខែអស្សុជ ឆ្នាំម្សាញ់ បញ្ចស័ក ព.ស.២៥៤៧

**ភិក្ខុសីលប្បញ្ញោ ឆៃ សុផល្លី**

# បញ្ជីមាតិកា


បុណ្យកើតអំពីការចម្រើនភាវនា . ..... ..... .... ..... ...... ១
ភិក្ខុព្យាយាមចំរើនភាវនារមែងផុតចាកអាសវៈធម៌...... ៣
បុញ្ញវិបាកសូត្រ ... ... ... ... ... . ... ... ... ..... ... ... ... ... ... ៧
និព្វិទាសូត្រ ... ... ... ... ... . ... ... ... ..... ... ... ... ... ... .. ១៣
អាសវក្ខយសូត្រ ... ... ... ... .... ... ... ... ... ... ... ... ... ... ១៤
សមាធិសូត្រ ... ... . ... ... ... ... . ... ...... ... ... ... ... ... ... ១៥
បធានសូត្រ ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ១៩
ទិដ្ឋិសូត្រ ... ... ... ... ... ... ... .. ... .... ... ... ... ... ... ... ... ២០
និទ្ទាតន្ទិសូត្រ ... ... ... ... ... ... ... ... ... ... ... ... ... ... ... ២១
ភាវនាសូត្រ ... ... ... ... ... ... ... ... . .. ... ... ... ... ... ... ... ២២
ចង្កមសូត្រ ... ... ... .... ... ... ... ... ... ... .. ... ... ... ... ... ២៦
អង្គសូត្រ ... ... ... ... ... ... ... ... ... ... ... .. ... ... ... ... ... ២៧
រឿងបរិនិព្វានរបស់ព្រះគោធិកត្ថេរ ... .. ... ... ... ... ... ២៨
ឧដ្ឋានសូត្រ ... ... ... ... ... ... ... ... ... ... ... .. ... ... ... ... ៣៣
សំវរសូត្រ ... ... ... ... ... ... ... ... ... ... ... .. ... ... ... ... .. ៣៤
បធានសូត្រ ... ... ... ... ... ... ... .. ... .... ... ... ... ... ... .. ៣៩
ចារសូត្រ ... ... ... ... . ... ... ... ..... ... ... ... ... ... ... ... ... ៤២
សីលសូត្រ ... ... ... ..... .... ... ..... .. ... ... ... ... ... ... ... ៤៧
បឋមធម្មវិហារកសូត្រ ... ...... ... .... ... ... ... ... ... ... ... ៥២

បឋមអនាគតសូត្រ ... ... .. ... ... ... .... ... ... ... ... ... ... ៥៥
រឿងព្រះមហាមិត្តត្ថេរ .. ... ... ... ... ... ... ... ... ... ... ... ៦០
វិត្ថារសូត្រ ... ... ... ... .... ... ... ... ... . ... ... ... ... ... .. ... ៦៣
បឋមសេក្ខសូត្រ ... ... ... ... ... ... .... ... ... ... ... ... ... ... ៦៨
លក្ខណៈជាដើមរបស់ការនាកុសល ... ... ... ... ... ... ៧០
បដិក្ខេបធម៌ជាដើមរបស់ការនាកុសល .. ...... ... ... ... ៧១
អប់រំចិត្ត ... ... ... ... ... ... ... ... ... ... ... ... .. ... ... ... ... .... ៧១
សមាធិជួយឱ្យស្ងប់ ... ... ... .... ... .. ... ... ... ... ... ...... ..៧៣
គម្ពីរជាឧបករណ៍ក្នុងការរៀបរៀងសៀវភៅនេះ ... ... ៧៤



ចិត្តវិវេក ចិត្តស្ងប់ ចិត្តស្អាត ចិត្តបរិសុទ្ធ

ចិត្តសូន្យប្រកាន់ សូន្យកង្វល់

ចិត្តសូន្យនិមិត្ត សូន្យជំពាក់

ចិត្តសូន្យកិលេស ⇨ សូន្យសៅហ្មងគឺរស់នៅស្រាលៗ គ្មានទម្ងន់ រស់នៅធូរៗគ្មានចំណងរួបរឹត

មានសីលបរិសុទ្ធ ⇨ ជាទីពឹង

មានវិបស្សនាបញ្ញា ⇨ ជាទីរលឹក

មានទិដ្ឋិវិមុត្តិ ⇨ ជាទីបង្អែក ។

# អារម្ភ

## កូនជាទីស្រឡាញ់ !!!

កូនត្រូវសិក្សានូវចំណុចនៃការនាទាំង ៨ នេះគឺៈ

១- បាបកើតពីអារម្មណ៍ណា គប្បីធ្វើចិត្តឱ្យឃ្លាតចាកពីអារម្មណ៍នោះ ។

២- ចូរត្រេកអរក្នុងការមិនធ្វេសប្រហែស ត្រូវតាមរក្សាចិត្តរបស់ខ្លួន ។

៣- ពន្លឺភ្លឺស្វាងស្មើដោយបញ្ញាមិនមានឡើយ ។

៤- បញ្ញានាំឱ្យបានដឹងនូវគុណតម្លៃនៃអប្បមាទធម៌ ។

៥- ឈើខ្លឹមគ្រប់ដើមមិនមែនបានធំក្នុងពេលត្រឹមតែ១ឆ្នាំនោះទេ ។

៦- ព្យាយាមនិងអំណត់ ជាគ្រូបង្ហាត់ដ៏ធំក្នុងលោក ។

៧- ជីវិតគឺការដើរផ្លូវឆ្ងាយ រូបរាងកាយជាសាលាសំណាក់ ។

៨- ពេលវេលាទំពាស៊ីអស់សព្វសត្វព្រមទាំងខ្លួនរបស់វា ។

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។
## សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ អង្គនោះ។

# ភាវនាមយ:

## *បុណ្យកើតអំពីការចម្រើនភាវនា*

*ក្នុងអដ្ឋកថាបរមត្ថទីបនីថា **ចេតនារបស់អ្នកពិចារណា** ឃើញច្បាស់នូវចក្ខុ សោត: ឃាន: ជិវ្ហា កាយ មន: ដោយ(ជារបស់)មិនទៀង ជាទុក្ខ ជាអនត្តា ដោយវិបស្សនាមគ្គដែលពោលហើយក្នុងបដិសម្ភិទា ១ ចេតនារបស់អ្នកពិចារណាឃើញច្បាស់នូវរូបទាំងឡាយ ។ល។ ធម៌ទាំងឡាយចក្ខុវិញ្ញាណ ។ល។ មនោ-វិញ្ញាណ ។ ចក្ខុសម្ផស្ស ។ល។ មនោសម្ផស្ស ចក្ខុសម្ផស្ស ជាវេទនា ។ល។ មនោសម្ផស្សជាវេទនា ។ រូបសញ្ញា ។ល។ ធម្មសញ្ញា ។ (និង)ជរាមរណ: ដោយជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ១ ឈាន ចេតនាដែលប្រព្រឹត្តទៅហើយក្នុងអារម្មណ៍ ៣៨ ប្រការ មានបឋវីកសិណជាដើម ១ ចេតនាដែលប្រព្រឹត្តទៅហើយដោយអំណាចនៃការសន្សំ(បរិច្ចយ) និងមនសិការជាដើមដែលមិនមានទោស ១ យ៉ាងណា អ្នកញុំាងចេតនាទាំងអស់នោះឱ្យចម្រើន ដោយបុញ្ញកិរិយាវត្ថុនេះ ព្រោះដូច្នោះ ទើបឈ្មោះថាបុញ្ញកិរិយាវត្ថុ ដែលសម្រេចដោយភាវនាតាមន័យដែលពោល*

ហើយ ដូច្នេះឯង ។

(ម្យ៉ាងទៀត) ការឱ្យ(ទាន) ដោយផ្ដើមតាំងការពិចារណា (នាមរូប) ដោយការអស់ទៅ ដោយការសូន្យទៅដោយកម្ម-បុញ្ញកិរិយាវត្ថុ **ជាភាវនាមយៈ** ។

ក្នុងបរមត្ថជោតិកថា **ភាវនា** សម្ដែងវចនត្ថៈថា:

**កុសលធម្មេ ភាវេតិ ឧប្បាទេតិ វឌ្ឍេតីតិ = ភាវនា** ធម្មជាតិណា ធ្វើឲ្យកុសលដែលប្រសើរឲ្យកើតឡើងជាគ្រាដំបូង ហើយធ្វើឲ្យចម្រើនឡើងដូច្នេះ ធម្មជាតិនោះ ឈ្មោះថា **ភាវនា** បានដល់ មហាកុសលចិត្តុប្បាទ ដែលជាប់ទាក់ទងនឹងការចម្រើន សមថភាវនា និងវិបស្សនាភាវនា ដែលនៅជាបរិកម្មភាវនា និង ឧបចារភាវនា ។

ក្នុងវចនត្ថៈនេះចែកជា ២ ផ្នែកគឺ៖

**កុសលធម្មេ ភាវេតិ ឧប្បទេតិ** រមែងធ្វើកុសលដែល ប្រសើរកើតឡើងគ្រាដំបូង ១ ផ្នែក,

**កុសលធម្មេ ភាវេតិ វឌ្ឍេតិ** រមែងធ្វើកុសលដែល ប្រសើរ កើតឡើងច្រើនទៅក្រៃលែងឡើងៗ១ ផ្នែក ។

វចនត្ថៈទាំង ២ ផ្នែកនេះ ផ្នែកទី ១ សំដៅដល់កុសល ចិត្តុប្បាទដែលកើតឡើងគ្រាដំបូងនៃការបដិបត្តិ, ផ្នែកទី ២ សំដៅ ដល់កុសលចិត្តុប្បាទ ដែលកើតឡើងជាប់តគ្នាក្នុងគ្រាក្រោយនៃ

ការបដិបត្តិដែលនៅមិនទាន់ចូលដល់អប្បនា ។

មួយទៀត ពាក្យថា **ភាវនាក្នុងបុញ្ញកិរិយាវត្ថុនោះ** លោកសម្តែងដល់រឿងមហាកុសល ដូច្នោះ អង្គធម៌ទើបបានដល់ មហា-កុសលតែម្យ៉ាង ចំណែកពាក្យថា **ភាវនា** ក្នុងកម្មដ្ឋានសង្គហៈ បរិច្ឆេទទី ៩ នោះ លោកសម្តែងដល់រឿងសមថ និងវិបស្សនា ដូច្នោះ អង្គធម៌ទើបបានដល់ លោកិយៈ និងលោកុត្តរៈកុសល ទាំងអស់តាមសមគួរដូច្នោះ ដីកាចារ្យទើបពោលទុកថា ការសិក្សារៀនសូត្រព្រះធម៌វិន័យ ការអប់រំ ការនឹកគិត ពិចារណាគិតសញ្ជឹងក្នុងគោលធម៌ផ្សេងៗក្តី ការរៀន ការអប់រំវិជ្ជាផ្សេងៗ ដែលមិនមានទោសទាំងនេះក្តី សុទ្ធសឹងតែជាភាវនាដែលជាចំណែកបុញ្ញកិរិយាវត្ថុទាំងអស់ ។

## ភិក្ខុព្យាយាមចំរើនភាវនាមែនផុតចាកអាសវៈធម៌

នៅក្នុងភាវនាសូត្រ ព្រះត្រៃបិដកលេខ ៤៧ ទំព័រ ២២៦ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់អំពីការចំរើនភាវនាអប់រំចិត្តរបស់ភិក្ខុក្នុងជីវិតប្រក្រតីរាល់ថ្ងៃ អាចធ្វើឱ្យអស់នូវអាសវៈកិលេសបាន ដូចមានព្រះសូត្រសម្តែងខាងក្រោមនេះ៖

ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមិនប្រកបរឿយៗនូវភាវនា បើទុកជាមានសេចក្តីប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ចិត្តរបស់អាត្មាអញគប្បីផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់

មាំ ដូច្នេះក៏ដោយ ក៏គង់ចិត្តរបស់ភិក្ខុនោះមិនរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះតែមិនប្រកាន់មាំដែរ។ ដំណើរនោះ ព្រោះហេតុអ្វី។ ត្រូវនិយាយថា ព្រោះតែភិក្ខុមិនបានចម្រើន ។ ព្រោះមិនបានចម្រើនអ្វី ។ ព្រោះតែមិនបានចម្រើនសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ។ ម្នាលភិក្ខុទាំងឡាយ ដូចពងមាន់ទាំងឡាយ ៨ ក្តី ១០ ក្តី ១២ ក្តី ពងមាន់ទាំងឡាយនោះ ដែលមេមាន់មិនក្រាបដោយប្រពៃ មិនបានធ្វើឱ្យកក់ក្តៅដោយប្រពៃ មិនបានឱ្យជាប់ក្លិនវាជាមេដោយប្រពៃ បើទុកជាមេមាន់នោះ មានសេចក្តីប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ កូនទាំងឡាយរបស់អញ គប្បីទម្លាយសំបកពងដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយស្រួល ដូច្នេះក៏ដោយ ក៏គង់តែកូនមាន់ទាំងនោះមិនអាចនឹងទម្លាយសំបកពង ដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយស្រួលបានដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះពងទាំងនោះ ដែលមេមាន់មិនក្រាបដោយប្រពៃ មិនបានធ្វើឱ្យកក់ក្តៅដោយប្រពៃ មិនបានឱ្យជាប់ក្លិនវាជាមេដោយប្រពៃ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមិនប្រកបរឿយៗនូវភាវនា បើទុកជាមានសេចក្តីប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ចិត្តរបស់អាត្មាអញគប្បី

ផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ដូច្នេះក៏ដោយ ក៏គង់ចិត្តរបស់ភិក្ខុនោះ មិនរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះតែមិនប្រកាន់មាំដែរ ។ ដំណើរនោះព្រោះហេតុអ្វី ។ ត្រូវនិយាយថា ព្រោះតែមិនបានចម្រើន ។ ព្រោះមិនបានចម្រើនអ្វី ។ ព្រោះមិនបានចម្រើនសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ យ៉ាងនោះដែរ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបានប្រកបរឿយៗនូវភាវនា បើទុកជាមិនមានសេចក្ដីប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ ចិត្តរបស់អាត្មាអញគប្បីផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ដូច្នេះក៏ដោយ ក៏គង់ចិត្តរបស់ភិក្ខុនោះរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះតែមិនប្រកាន់មាំដែរ ។ ដំណើរនោះព្រោះហេតុអ្វី ។ ត្រូវនិយាយថា ព្រោះតែភិក្ខុបានចម្រើន ។ ព្រោះបានចម្រើនអ្វី ។ ព្រោះបានចម្រើនសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ៨ ។ ម្នាលភិក្ខុទាំងឡាយ ដូចពងមាន់ទាំងឡាយ ៨ ក្ដី ១០ ក្ដី ១២ ក្ដី ពងមាន់ទាំងឡាយនោះ ដែលមេមាន់ក្រាបដោយប្រពៃហើយ ធ្វើឱ្យកក់ក្ដៅដោយប្រពៃហើយ ធ្វើឱ្យជាប់ក្លិនវាជាមេដោយប្រពៃហើយ មេមាន់នោះបើទុកជាមិនមានសេចក្ដីប្រាថ្នា

យ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ កូនទាំងឡាយរបស់អញគប្បីទម្លាយសំបកពងដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយស្រួលដូច្នេះក៏ដោយ ក៏គង់តែកូនមាន់ទាំងនោះអាចទម្លាយសំបកពង ដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយស្រួលបាន ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះពងទាំងនោះ ដែលមេមាន់ក្រាបដោយប្រពៃហើយ ធ្វើឱ្យកក់ក្ដៅដោយប្រពៃហើយ ឱ្យជាប់ក្លិនវាជាមេដោយប្រពៃហើយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបានប្រកបរឿយៗនូវភាវនា បើទុកជាមិនមានសេចក្ដីប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ ចិត្តរបស់អាត្មាអញគប្បីផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំដូច្នេះក៏ដោយ ក៏គង់តែចិត្តរបស់ភិក្ខុនោះ ផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំបានដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ត្រូវនិយាយថា ព្រោះតែភិក្ខុបានចម្រើន ។ ព្រោះបានចម្រើនអ្វី ។ ព្រោះបានចម្រើនសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ក៏ យ៉ាងនោះដែរ ។

ម្នាលភិក្ខុទាំងឡាយ ដូចជាងឈើ ឬកូនសិស្សរបស់ជាងឈើ យកម្រាមដៃ និងមេដៃទៅចាប់កាន់ត្រង់មៀនកាំបិត ប៉ុន្តែ

ដាងឈើ ឬកូនសិស្សរបស់ជាងឈើនោះ មិនដឹងយ៉ាងនេះថា មៀនកាំបិតរបស់អញនោះ ថ្ងៃនេះសឹកអស់ប៉ុណ្ណោះ ឬថ្ងៃម្សិល សឹកអស់ប៉ុណ្ណោះ ឬថ្ងៃម្សិលម្ង៉ៃ សឹកអស់ប៉ុណ្ណោះ ដូច្នេះទេ លុះដល់មៀនកាំបិតនោះសឹកអស់ហើយ ទើបបានដឹងថា អស់ហើយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបានប្រកបរឿយៗនូវភាវនា បើទុកជាមិនបានដឹងយ៉ាងនេះថា ថ្ងៃនេះអាសវៈទាំងឡាយរបស់អញអស់ទៅប៉ុណ្ណោះ ឬថ្ងៃម្សិល អស់ទៅប៉ុណ្ណោះ ឬថ្ងៃម្សិលម្ងៃ អស់ទៅប៉ុណ្ណោះ ដូច្នេះទេ លុះអាសវៈនោះអស់ទៅ ទើបដឹងថាអស់ហើយ ក៏យ៉ាងនោះដែរ ។

ម្នាលភិក្ខុទាំងឡាយ ដូចសំពៅសមុទ្រដែលគេចងនឹងផ្តៅ ត្រាំនៅក្នុងទឹកអស់ ៦ ខែ ដល់ហេមន្តរដូវ គេលើកឡើងដាក់លើគោក ចំណងទាំងឡាយ ត្រូវខ្យល់និងកំដៅថ្ងៃ ចំណងទាំងនោះត្រូវភ្លៀងបង្អុរស្រោច ក៏ខូចពុកផុយបានដោយងាយ យ៉ាងណាមិញម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុបានប្រកបរឿយៗនូវភាវនា សំយោជនៈទាំងឡាយក៏ស្ងប់រម្ងាប់ បានដោយងាយ ក៏យ៉ាងនោះដែរ ។

## បុញ្ញវិបាកសូត្រ

នៅក្នុងព្រះត្រៃបិដកលេខ ៤៧ ទំព័រ ១៦៤ ព្រះអង្គទ្រង់ត្រាស់សម្តែងអានិសង្សរបស់ការចម្រើនមេត្តាភាវនា ជាមួយនឹង

ភិក្ខុទាំងឡាយថា៖

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំខ្លាចបុណ្យឡើយ ម្នាលភិក្ខុទាំងឡាយ ពាក្យថាបុណ្យនេះ ជាឈ្មោះនៃសេចក្ដីសុខ ។ ម្នាលភិក្ខុទាំងឡាយ តថាគតដឹងច្បាស់ តថាគតបានចំរើនមេត្តាចិត្ត ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាផលដែលបុគ្គលទទួលរឿយៗអស់ឆ្នាំ ៧ ជាយូរអង្វែង លុះតថាគតចំរើននូវមេត្តាចិត្តអស់៧ឆ្នាំហើយក៏មិនបានមកកាន់លោកនេះទៀត អស់សំវដ្តកប្បនិងវិវដ្តកប្ប ៧ ម្នាលភិក្ខុទាំងឡាយ កាលដែលលោកវិនាសទៅ តថាគតបានទៅកើតក្នុងអាភស្សរាព្រហ្ម កាលដែលលោកចំរើនឡើង តថាគតបានទៅកាន់ព្រហ្មវិមានដែលសូន្យ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងព្រហ្មវិមាននោះ តថាគតជាព្រហ្មជាមហាព្រហ្ម គ្របសង្កត់ព្រហ្មឯទៀត ព្រហ្មឯទៀតមិនអាចគ្របសង្កត់តថាគតបានទេ តថាគតជាអ្នកឃើញហេតុសព្វគ្រប់ ជាអ្នកធ្វើព្រហ្មទាំងពួង ឱ្យលុះក្នុងអំណាចខ្លួន ។

ម្នាលភិក្ខុទាំងឡាយ តថាគតបានកើតជាសក្កទេវរាជ ៣៦ ដង ។ តថាគតបានជាស្ដេចចក្រពត្តិ ប្រកបដោយធម៌ ជាធម្មរាជជាឥស្សរៈក្នុងផែនដី មានព្រំប្រទល់ក្នុងទីបំផុតនៃសមុទ្រទាំង ៤ មានជ័យជំនះដល់នូវភាវៈមាំមួនក្នុងជនបទ បរិបូណ៌ដោយរតនៈទាំង ៧ ប្រការ ជាច្រើនរយដង ។

ម្នាលភិក្ខុទាំងឡាយ រតនៈ ៧ ប្រការនេះកើតដល់តថាគត នោះ គឺចក្ករតនៈ ១ ហត្ថិរតនៈ ១ អស្សរតនៈ ១ មណិរតនៈ ១ ឥត្ថីរតនៈ ១ គហបតិរតនៈ ១ បរិនាយករតនៈ ១ ជាគម្រប់ ៧ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានកូនច្រើនពាន់ ជាអ្នកក្លៀវក្លា មានសភាពជាអ្នកមានសេចក្ដីព្យាយាម អាចញាំញីនូវសេនានៃស្ដេចដទៃបាន ។ តថាគតបានឈ្នះហើយ នៅគ្រប់គ្រងផែនដីនេះ ដែលមានសាគរជាទីបំផុត ដោយធម៌មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើគ្រឿងសស្ត្រាទេ ។

ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញនូវផលនៃបុណ្យជាកុសល ហើយក៏បានប្រាប់ពួកសត្វដែលជាអ្នកស្វែងរកសេចក្ដីសុខ ហើយចំរើននូវមេត្តាចិត្តអស់ ៧ ឆ្នាំ មិនបានមកកាន់លោកនេះទៀត អស់សំវដ្តកប្ប និងវិវដ្តកប្ប ៧ ដង កាលដែលលោកវិនាស តថាគតទៅកើតអាភស្សរព្រហ្ម កាលដែលលោកចំរើន តថាគតចូលទៅកាន់ព្រហ្មលោកដែលសូន្យ ក្នុងកាលនោះ តថាគតបានជាមហាព្រហ្ម ជាអ្នកធ្វើព្រហ្មឯទៀតឱ្យលុះក្នុងអំណាចនៃខ្លួនអស់ ៧ ដង បានជាស្ដេចនៃទេវតា ជាកំពូលនៃទេវតាអស់ ៣៦ ដង បានជាស្ដេចចក្រពត្តិ ជាធំក្នុងជម្ពូទ្វីប ។ បានជាក្សត្រដែលបានមុទ្ធាភិសេក ជាអធិបតីរបស់មនុស្ស បានឈ្នះនូវផែនដីនេះដោយធម៌ មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើ

គ្រឿងសស្ត្រា មិនបាច់កំហែងកំហល់ទេ បានប្រៀនប្រដៅដោយធម៌ដ៏ស្មើ ហើយបានសោយរាជសម្បត្តិនោះលើមណ្ឌលនៃផែនដីនេះដោយធម៌ តែងបានកើតក្នុងត្រកូលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន បរិបូណ៌ដោយកាមទាំងពួងផង ដោយរតនៈទាំង ៧ ផង ព្រះពុទ្ធទាំងឡាយជាអ្នកសង្គ្រោះពួកសត្វលោក ព្រះពុទ្ធទាំងនោះទ្រង់សម្តែងដោយប្រពៃនូវហេតុនុ៎ះ នេះជាហេតុហៅថា ជាម្ចាស់នៃផែនដីរបស់ជនដ៏ច្រើន តថាគតជាស្តេចមានទ្រព្យសម្បត្តិច្រើន ជាអ្នកអង់អាច ជាអ្នកមានឫទ្ធិ មានយស ជាឥស្សរៈក្នុងជម្ពូទ្វីប ។ បុគ្គលណាស្តាប់ហើយមិនជ្រះថ្លា ចាត់ជាកណ្ហាជាតិ ព្រោះហេតុនោះ បុគ្គលមានប្រាថ្នានូវប្រយោជន៍ ប្រាថ្នានូវភាវៈជាធំ រលឹកនូវព្រះពុទ្ធសាសនា គប្បីធ្វើនូវសេចក្តីគោរពនូវព្រះសទ្ធម្មចុះ ។

## អដ្ឋកថា

ពាក្យថា **មា ភិក្ខវេ បុញ្ញានំ ភាយិត្ថ** សេចក្តីថា ពួកលោកកាល នឹងធ្វើបុណ្យ កុំបានខ្លាចចំពោះបុណ្យទាំងនោះឡើយ ។

ដោយពាក្យថា **មេត្តចិត្តំ ភាវេសី** ព្រះដ៏មានព្រះភាគទ្រង់សម្តែងថា យើងអប់រំចិត្តធ្វើឱ្យប្រណិតប្រកបមេត្តា ប្រកបដោយឈាន ពួក ៣ និងពួក ៤ ពាក្យថា **សំវដ្តមានេ សុទាហំ** កាត់បទជា **សំវដ្តមានេ សុទំ អហំ** ។

បទថា **សំវដ្ដមានេ** សេចក្ដីថា កាលលោកត្រូវភ្លើងឆេះ គឺដែលភ្លើងធ្វើឱ្យវិនាស ។

បទថា **ធម្មិកោ** បានដល់ ប្រកបដោយកុសលធម៌ ១០ ប្រការ ។

បទថា **ធម្មរាជានេះ** ជាវេវចនៈរបស់បទថា ធម្មរាជា នោះ ។ មួយទៀត ឈ្មោះថា ជាធម្មរាជា ព្រោះទ្រង់បាន រាជសម្បត្តិដោយធម៌ ។

បទថា **ចាតុរន្តោ** បានដល់ មានភាពជាធំលើផែនដីដែល ឈ្មោះថា ចាតុរន្ត៍ ដោយអំណាចមានមហាសមុទ្រទាំង ៤ មាន ក្នុងទិសបូព៌ាជាដើម បទថា **វិជិតាវី** ប្រែថា អ្នកឈ្នះសង្គ្រាម ។ ជនបទក្នុងព្រះបាទចក្រពត្តិនោះ ដល់សេចក្ដីរឹងមាំជាថាវរ ព្រោះហេតុនោះ ទើបឈ្មោះថា អ្នកទ្រង់មានជនបទដល់សេចក្ដី រឹងមាំជា ថាវរ ។

បទថា **បរោសហស្សំ** ប្រែថា មានព្រះឱរសច្រើនលើស ១,០០០ ព្រះអង្គ ។

បទថា **សូរា** បានដល់ អ្នកមិនក្រាល ក្នុងបទថា **វីរង្គរូបា** មានរូបបទវិគ្រោះដូចតទៅនេះៈ

អង្គរបស់អ្នកក្លៀវក្លា ឈ្មោះថា វីរង្គៈ ។ វីរង្គៈអង្គអ្នក ខ្លាំងក្លាមិនជារូបរបស់ឱរសទាំងនោះ ហេតុនោះឱរសទាំងនោះ

ឈ្មោះថា **វិវដ្ដរូបា** អ្នកមានអង្គនៃអ្នកខ្លាំងក្លាមិនជារូប ។ លោកអធិប្បាយទុកថា ឱរសទាំងនោះ មិនខ្ជិលច្រអូស ដូចអ្នកមានសេចក្ដីព្យាយាមជាប្រក្រតី មានសេចក្ដីព្យាយាមជាសភាវៈ និងមានសេចក្ដីព្យាយាខ្លាំង ។ លោកអធិប្បាយថា សូម្បីទាំងថ្ងៃក៏មិននឿយហត់ ។

បទថា **សាគរបរិយន្តំ** សេចក្ដីថា មានមហាសមុទ្រនិងភ្នំខ្ពស់ ចក្រវាឡជាព្រំដែនលោមព័ទ្ធជុំវិញ ។

បទថា **អទណ្ឌេន** បានដល់ វៀរចាកអាជ្ញា គឺការពិន័យតម្លៃទ្រព្យដោយទ្រព្យខ្លះ ចុះអាជ្ញាផ្លូវបទនិតិបញ្ញត្តិ ដោយបង្គាប់ឲ្យកាត់ដៃជើង និងប្រហារជីវិតខ្លះ បទថា **អសត្ថេន** បានដល់ វៀរចាកប្រើសស្ត្រា បៀតបៀនអ្នកដទៃ ដោយសស្ត្រាមានមុតខាងតែម្ខាងជាដើម បទថា **ធម្មេន អភិវិជ័យ** សេចក្ដីថា ទ្រង់ឈ្នះនូវផែនដី មានប្រការដូចពោលហើយ ដោយធម៌តែម្យ៉ាងដោយន័យមានជាដើមថា មិនគប្បីសម្លាប់បាណៈសត្វដែលព្រះរាជាអ្នកជាសត្រូវ ទទួលស្ដេចយ៉ាងនេះថា បពិត្រមហារាជ សូមព្រះអង្គមេត្តាស្ដេចមកចុះ ។

បទថា **សុខេសិនំ** សេចក្ដីថា រមែងហៅសត្វទាំងឡាយអ្នកស្វែងរកសេចក្ដីសុខ ។

បទថា **សុញ្ញព្រហ្មូបគោ** សេចក្ដីថា អ្នកចូលដល់វិមាន

របស់ព្រះព្រហ្មដែលទទេ ។

បទថា **បឋវី ឥមំ** សេចក្ដីថា នូវផែនដីធំ ដែលមានសាគរជាទីបំផុត ។

បទថា **អសាហសេន** បើពោលអំពីកម្ម ដែលមិនបានគិត ។

បទថា **សមេន សុទេសិតំ** សេចក្ដីថា ទូន្មានដោយកម្មដ៏ស្មើ ។

បទថា **តេហិ ឯតំ សុទេសិតំ** សេចក្ដីថា ឋានៈនេះ គឺមានប្រមាណប៉ុណ្ណោះ ដែលព្រះពុទ្ធទាំងឡាយសម្ដែងល្អហើយ ត្រាស់ល្អហើយ ។

បទថា **បញ្ញោ** ប្រែថា ម្ចាស់ផែនដី ។

## និព្វិទាសូត្រ

នៅក្នុងព្រះត្រៃបិដកលេខ ៤៤ ទំព័រ ១៦៩ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពី ធម៌ដែលអំណោយផលឱ្យសម្រេចនូវព្រះនិព្វាន សេចក្ដីថា៖

ម្នាលភិក្ខុទាំងឡាយ ធម៌៥យ៉ាងនេះ ដែលភិក្ខុបានចម្រើន បានធ្វើឱ្យរឿយៗហើយ រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីសេចក្ដីរលត់ដោយមិនសល់ ដើម្បីរម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីព្រះនិព្វាន ។ ធម៌ ៥ យ៉ាង តើដូចម្ដេច ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកឃើញរឿយៗថា មិនស្អាតក្នុងកាយ ១

-សម្គាល់ថា គួរខ្ពើមក្នុងអាហារ ១

-សម្គាល់ថា មិនគួរត្រេកត្រអាលក្នុងលោកទាំងពួង ១

-ឃើញរឿយៗថា មិនទៀងក្នុងសង្ខារទាំងពួង ១

-ទាំងមរណសញ្ញា ក៏ប្រាដកឡើងខាងក្នុងចិត្តរបស់ភិក្ខុនោះ ដោយប្រពៃ ១។

ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ដែលបុគ្គលបានចំរើន បានធ្វើឱ្យរឿយៗហើយ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយដោយចំណែកមួយ ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់មិនសល់ ដើម្បីរម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីព្រះនិព្វាន ។

**អាសវក្ខយសូត្រ**

នៅក្នុងព្រះត្រៃបិដកលេខ ៤៤ ទំព័រ ១៧០ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពី ធម៌ដែលអំណោយផលឱ្យអស់អាសវៈ សេចក្តីថា៖

ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ដែលភិក្ខុបានចម្រើន បានធ្វើឱ្យរឿយៗហើយ រមែងប្រព្រឹត្តទៅដើម្បីអស់ទៅនូវអាសវទាំងឡាយ ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកឃើញរឿយៗថា មិនស្អាតក្នុងកាយ ១

-សម្គាល់ថា គួរខ្ពើមក្នុងអាហារ ១

-សម្គាល់ថា មិនគួរត្រេកត្រអាលក្នុងលោកទាំងពួង ១

-ឃើញរឿយៗថា មិនទៀងក្នុងសង្ខារទាំងពួង ១

-ទាំងមរណសញ្ញា ក៏ប្រាដកឡើងខាងក្នុងចិត្តរបស់ភិក្ខុនោះដោយប្រពៃ ១។

ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ដែលបុគ្គលបានចំរើន បានធ្វើឱ្យរឿយៗហើយ រមែងប្រព្រឹត្តទៅដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ។

## សមាធិសូត្រ

នៅក្នុងព្រះត្រៃបិដកលេខ ៤២ ទំព័រ ១០៨ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពីសមាធិភាវនា ៤យ៉ាង មានសេចក្តីថា

ម្នាលភិក្ខុទាំងឡាយ សមាធិភាវនានេះមាន ៤ យ៉ាង ។ សមាធិភាវនា ៤ យ៉ាង តើដូចម្តេចខ្លះ ។

ម្នាលភិក្ខុទាំងឡាយ សមាធិភាវនាដែលបុគ្គលបានចំរើន បានធ្វើឱ្យរឿយៗហើយ ប្រព្រឹត្តទៅដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន ១។

ម្នាលភិក្ខុទាំងឡាយ សមាធិភាវនាដែលបុគ្គលបានចំរើន បានធ្វើឱ្យរឿយៗហើយ ប្រព្រឹត្តទៅដើម្បីបាននូវញាណទស្សនៈ ១។

ម្នាលភិក្ខុទាំងឡាយ សមាធិភាវនាដែលបុគ្គលបានចំរើន បានធ្វើឱ្យរឿយៗហើយ ប្រព្រឹត្តទៅដើម្បីសតិនិងសម្បជញ្ញៈ ១។

ម្នាលភិក្ខុទាំងឡាយ សមាធិភាវនាដែលបុគ្គលបានចំរើន បានធ្វើឱ្យរឿយៗហើយ ប្រព្រឹត្តទៅដើម្បីអស់ទៅនៃអាសវៈទាំងឡាយ១ ។

## សេចក្តីអធិប្បាយសមាធិភាវនាទាំង ៤ យ៉ាង

ម្នាលភិក្ខុទាំងឡាយ ចុះសមាធិភាវនាដែលបុគ្គលបានចម្រើន បានធ្វើឱ្យរឿយៗហើយ ប្រព្រឹត្តទៅដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន ១ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកធម៌ជាអកុសលទាំងឡាយ ហើយបានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារ មានបីតិ និងសុខដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ជាអារម្មណ៍ សម្រេចសម្រាន្តនៅ ព្រោះរម្ងាប់នូវវិតក្កៈ និងវិចារៈ ក៏ចូលទៅកាន់ទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯង មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខកើតអំពីសមាធិ គឺបឋមជ្ឈាន សម្រេចសម្រាន្តនៅ ព្រោះប្រាសចាកបីតិផង ជាបុគ្គលព្រងើកន្តើយផង មានសតិនិងសម្បជញ្ញៈផង ទទួលយកនូវសុខដោយនាមកាយផង ព្រះអរិយទាំងឡាយ តែងសរសើរនូវព្រះអរិយបុគ្គលដែលបាននូវតតិយជ្ឈាននោះថា ប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ ជាគ្រឿងនៅសុខដូច្នេះ ព្រោះតតិយជ្ឈានណា ក៏បាននូវតតិយជ្ឈាននោះ សម្រេចសម្រាន្តនៅ ព្រោះលះបង់នូវសុខផង លះបង់នូវសេចក្តីទុក្ខផង មានសោមនស្ស និងទោមនស្សអស់ទៅក្នុងកាលមុនផង ក៏បានដល់

នូវចតុត្ថជ្ឈាន ជាធម្មតា មានអារម្មណ៍ មិនមែនជាទុក្ខ មិនមែនជាសុខ គឺជាឧបេក្ខា មានសតិដ៏បរិសុទ្ធដោយឧបេក្ខា សម្រេចសម្រាន្តនៅ ។

ម្នាលភិក្ខុទាំងឡាយ នេះជាសមាធិភាវនាដែលបុគ្គលបានចំរើន បានធ្វើឱ្យរឿយៗហើយ ប្រព្រឹត្តទៅដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន ។

ម្នាលភិក្ខុទាំងឡាយ ចុះសមាធិភាវនាដែលបុគ្គលបានចំរើន បានធ្វើឱ្យរឿយៗហើយ ប្រព្រឹត្តទៅដើម្បីបាននូវញាណទស្សនៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះធ្វើទុកក្នុងចិត្តនូវអាលោកសញ្ញា (សេចក្តីសម្គាល់ក្នុងពន្លឺ) អធិដ្ឋាននូវទិវាសញ្ញា (សេចក្តីសម្គាល់ក្នុងវេលាថ្ងៃ) គឺថាក្នុងវេលាថ្ងៃយ៉ាងណា វេលាយប់ក៏យ៉ាងនោះ ក្នុងវេលាយប់យ៉ាងណា វេលាថ្ងៃក៏យ៉ាងនោះដែរ ។ ភិក្ខុមានចិត្តស្ងប់ស្ងាត់ មិនមានកិលេសជាគ្រឿងរួបរឹត តែងចំរើនចិត្តដែលប្រកបដោយពន្លឺដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សមាធិភាវនាដែលបុគ្គលបានចម្រើន បានធ្វើឱ្យរឿយៗហើយ ប្រព្រឹត្តទៅដើម្បីបាននូវញាណទស្សនៈ ។

ម្នាលភិក្ខុទាំងឡាយ ចុះសមាធិភាវនាដែលបុគ្គលបានចម្រើនបានធ្វើឱ្យរឿយៗហើយ ប្រព្រឹត្តទៅដើម្បីសតិនិងសម្បជញ្ញៈ

តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ វេទនារបស់ភិក្ខុទាំងឡាយក្នុងសាសនានេះ តែងកើតឡើងប្រាកដ តែងឋិតនៅប្រាកដ តែងដល់នូវសេចក្តីអស់ទៅវិញប្រាកដ សញ្ញា(ទាំងឡាយតែងកើតឡើងប្រាកដ តែងឋិតនៅប្រាកដ តែងដល់នូវសេចក្តីអស់ទៅវិញប្រាកដ) វិតក្កៈទាំងឡាយ តែងកើតឡើងប្រាកដ តែងឋិតនៅប្រាកដ តែងដល់នូវសេចក្តីអស់ទៅវិញប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ នេះជាសមាធិភាវនាដែលបុគ្គលបានចំរើន បានធ្វើឱ្យរឿយៗ ហើយ ប្រព្រឹត្តទៅដើម្បីសតិនិងសម្បជញ្ញៈ ។

ម្នាលភិក្ខុទាំងឡាយ ចុះសមាធិភាវនាដែលបុគ្គលបានចំរើន បានធ្វើឱ្យរឿយៗហើយ ប្រព្រឹត្តទៅដើម្បីអស់ទៅនៃអាសវៈទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយៗនូវទីកើត និងទីរលត់ក្នុងឧបាទានក្ខន្ធទាំង ៥ ថា រូបដូច្នេះ ការកើតឡើងនៃរូបដូច្នេះ សេចក្តីអស់ទៅនៃរូបដូច្នេះ វេទនាដូច្នេះ ការកើតឡើងនៃវេទនាដូច្នេះ សេចក្តីអស់ទៅនៃវេទនាដូច្នេះ សញ្ញាដូច្នេះ ការកើតឡើងនៃសញ្ញាដូច្នេះ សេចក្តីអស់ទៅនៃសញ្ញាដូច្នេះ សង្ខារទាំងឡាយដូច្នេះ ការកើតឡើងនៃសង្ខារទាំងឡាយដូច្នេះ សេចក្តីអស់ទៅនៃសង្ខារទាំងឡាយដូច្នេះ វិញ្ញាណដូច្នេះ ការកើតឡើងនៃវិញ្ញាណដូច្នេះ សេចក្តីអស់ទៅនៃវិញ្ញាណដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ

នេះជាសមាធិភាវនាដែលបុគ្គលបានចំរើន បានធ្វើឱ្យរឿយៗហើយ ប្រព្រឹត្តទៅដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ។

ម្នាលភិក្ខុទាំងឡាយ សមាធិភាវនាមាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ តថាគតបានពោលហើយក្នុងបុណ្ណកប្បញ្ហា ត្រង់បរាយនវគ្គ ព្រោះសំដៅយកសមាធិភាវនានុ៎ះ។

**សង្ខាយ លោកស្មឹ បរោបរានិ**
**យស្សិញ្ជិតំ នត្ថិ កុហិញ្ចិ លោកេ**
**សន្តោ វិធូមោ អនិឃោ និរាសោ**
**អតារិ សោ ជាតិជរន្តិ ព្រូមីតិ ។**

បុគ្គលបានពិចារណានូវសភាពធម៌ដ៏ថោកទាប និងឧត្តមក្នុងលោក សេចក្តីរំភើបចិត្តបន្តិចបន្តួចរបស់បុគ្គលណាមិនមានក្នុងលោក តថាគតពោលថា បុគ្គលនោះជាអ្នករម្ងាប់(នូវសឹកសត្រូវគឺកិលេស)មិនមាន ផ្សែងគឺសេចក្តីក្រោធមិនមាន ទុក្ខមិនមាន សេចក្តីប្រាថ្នា ឈ្មោះថា ឆ្លងនូវជាតិ និងជរាបាន ។

## **បធានសូត្រ**

នៅក្នុងព្រះត្រៃបិដកលេខ ៤២ ទំព័រ ១៨៩ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពី ធម៌ជាហេតុអស់អាសវៈ ៤ ប្រការមានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ប្រការឈ្មោះ

ថា ជាអ្នកប្រតិបត្តិចំពោះអបណ្ណកបដិបទា គឺប្រតិបត្តិមិនខុស ផង ភិក្ខុនោះឈ្មោះថាជាអ្នកប្រារព្ធហេតុដើម្បីអស់ទៅនៃអាសវៈ ទាំងឡាយផង ។ ធម៌ ៤ ប្រការដូចម្តេចខ្លះ ។

***-ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ*** ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងសាសនានេះ ជាអ្នកមានសីល ១

***-ពហុស្សុតោ ហោតិ*** ជាអ្នកចេះដឹងច្រើន ១

***-អារទ្ធវិរិយោ ហោតិ*** ជាអ្នកមានព្យាយាមប្រារព្ធ ១

***-បញ្ញវា ហោតិ*** ជាអ្នកមានប្រាជ្ញា ១។

## ទិដ្ឋិសូត្រ

នៅក្នុងព្រះត្រៃបិដកលេខ ៤២ ទំព័រ ១៨៩ ព្រះមានព្រះ ភាគជាម្ចាស់ទ្រង់ត្រាស់អំពីធម៌ជាហេតុអស់អាសវៈ ៤ ប្រការ មានសេចក្តីថា៖

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ប្រការ ឈ្មោះ ថា ជាអ្នកប្រតិបត្តិនូវអបណ្ណកប្បដិបទា ភិក្ខុនោះឈ្មោះថា ជា អ្នកប្រារព្ធហេតុ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយផង ។ ធម៌ ៤ ប្រការដូចម្តេចខ្លះ ។

***-នេក្ខម្មវិតក្កេន*** គឺសេចក្តីត្រិះរិះក្នុងការចេញចាកកាម ១

***-អព្យាបាទវិតក្កេន*** សេចក្តីត្រិះរិះក្នុងការមិនព្យាបាទ ១

***-អវិហឹសាវិតក្កេន*** សេចក្តីត្រិះរិះក្នុងការមិនបៀតបៀន ១

-**សម្មាទិដ្ឋិយា** សេចក្តីយល់ឃើញត្រូវ ១។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ប្រការនេះ ឈ្មោះថា ជាអ្នកប្រតិបត្តិនូវអបណ្ណកប្បដិបទាផង ភិក្ខុនោះឈ្មោះថា ជាអ្នកប្រារព្ធហេតុដើម្បីអស់ទៅនៃអាសវៈទាំងឡាយផង ។

## និទ្ទាតន្ទិសូត្រ

នៅក្នុងព្រះត្រៃបិដកលេខ ២៩ ទំព័រ ១៦ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពីមគ្គប្រាកដនិងមិនប្រាកដ ដោយទេវតាទូលសួរថា៖

**ឋិតេ មជ្ឈន្តិកេ កាលេ សន្និសិន្នេសុ បក្ខិសុ**
**សណតេវ មហារញ្ញំ តំ ភយំ បដិភាតិ មន្តិ ។**

ក្នុងកាលកំពុងថ្ងៃត្រង់ ហ្វូងសត្វបក្សីទំសម្រាក ព្រៃធំហាក់ដូចព្យុសូររំពងខ្លាំង សូរសន្ធឹកនោះឯង ជាភ័យប្រាកដជាក់ស្តែងដល់ខ្ញុំព្រះអង្គ ។

ព្រះអង្គទ្រង់ត្រាស់ថា:

**ឋិតេ មជ្ឈន្តិកេ កាលេ សន្និសិន្នេសុ បក្ខិសុ**
**សណតេវ មហារញ្ញំ សា រតី បដិភាតិ មន្តិ។**

ក្នុងកាលកំពុងថ្ងៃត្រង់ ហ្វូងសត្វបក្សីទំសម្រាក ព្រៃធំហាក់ដូចព្យុសូររំពងខ្លាំង ការអង្គុយម្នាក់ឯងនោះ ជាសេចក្តីត្រេកអរប្រាកដដល់តថាគត ។

# ភាវនាសូត្រ

នៅក្នុងព្រះត្រៃបិដកលេខ ៤៧ ទំព័រ ២២៦ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពី ភិក្ខុព្យាយាមចំរើនភាវនារមែងរួចផុតទុក្ខ មានសេចក្ដីថា៖

ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមិនប្រកបរឿយៗនូវភាវនា បើទុកជាមានសេចក្ដីប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ ចិត្តរបស់អាត្មាអញគប្បីផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំដូច្នេះក៏ដោយ ក៏គង់តែចិត្តរបស់ភិក្ខុនោះ មិនផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះហេតុមិនប្រកាន់មាំដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ត្រូវនិយាយថា ព្រោះតែភិក្ខុមិនបានចំរើន ។ ព្រោះមិនបានចំរើនអ្វី ។ ព្រោះតែមិនបានចំរើនសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ។ ម្នាលភិក្ខុទាំងឡាយ ដូចពងមាន់ទាំងឡាយ ៨ ក្ដី ១០ ក្ដី ១២ ក្ដី ពងមាន់ទាំងឡាយនោះ ដែលមេមាន់មិនក្រាបដោយប្រពៃ មិនបានធ្វើឱ្យកក់ក្ដៅដោយប្រពៃ មិនបានឱ្យជាប់ក្លិនវាជាមេដោយប្រពៃ បើទុកជា មេមាន់នោះ មានសេចក្ដីប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ កូនទាំងឡាយរបស់អញគប្បីទម្លាយសំបកពង ដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយស្រួល ដូច្នេះក៏

ដោយ ក៏គង់តែកូនមាន់ទាំងនោះ មិនអាចនឹងទម្លាយនូវសម្បក ពងដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយស្រួលបានដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះពងទាំងនោះដែលមេមាន់ មិនបានក្រាបដោយប្រពៃ មិនបានធ្វើឱ្យកក់ក្តៅដោយប្រពៃ មិនបានឱ្យជាប់ក្លិនវាជាមេដោយប្រពៃ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមិនប្រកបរឿយៗនូវភាវនា បើទុកជាមានសេចក្តីប្រាថ្នាយ៉ាងនេះ ធ្វើដូចម្តេចហ្ន៎ ចិត្តរបស់អាត្មាអញគប្បីផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំដូច្នេះក៏ដោយ ក៏គង់តែចិត្តរបស់ភិក្ខុនោះ មិនផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះតែមិនបានប្រកាន់មាំដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ត្រូវនិយាយថា ព្រោះតែមិនបានចំរើន ។ ព្រោះមិនបានចំរើនអ្វី ។ ព្រោះតែមិនបានចំរើនសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ យ៉ាងនោះដែរ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបានប្រកបរឿយៗនូវភាវនា បើទុកជាមិនមានសេចក្តីប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ចិត្តរបស់អាត្មាអញគប្បីផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំដូច្នេះក៏ដោយ ក៏គង់តែចិត្តរបស់ភិក្ខុនោះ ផុតស្រឡះ

ចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ត្រូវនិយាយថា ព្រោះតែភិក្ខុបានចំរើន ។ ព្រោះបានចំរើនអ្វី ។ ព្រោះតែបានចំរើនសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ។ ម្នាលភិក្ខុទាំងឡាយ ដូចពងមាន់ទាំងឡាយ ៨ ក្តី ១០ ក្តី ១២ ក្តី ពងមាន់ទាំងឡាយនោះ ដែលមេមាន់ក្រាបដោយប្រពៃហើយ បានធ្វើឱ្យកក់ក្តៅដោយប្រពៃហើយ បានឱ្យជាប់ក្លិនវាជាមេដោយប្រពៃហើយ មេមាន់នោះ បើទុកជាមិនមានសេចក្តីប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ កូនទាំងឡាយរបស់អញគប្បីទម្លាយសំបកពង ដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយស្រួល ដូច្នេះក៏ដោយ ក៏គង់តែកូនមាន់ទាំងនោះ អាចទម្លាយនូវសម្បកពងដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយស្រួលបាន ។ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះពងទាំងនោះដែលមេមាន់បានក្រាបដោយប្រពៃ បានធ្វើឱ្យកក់ក្តៅដោយប្រពៃហើយ បានឱ្យជាប់ក្លិនវាជាមេដោយប្រពៃហើយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបានប្រកបរឿយៗនូវភាវនា បើទុកជាមិនមានសេចក្តីប្រាថ្នាយ៉ាងនេះ ធ្វើដូចម្តេចហ្ន៎ ចិត្តរបស់អាត្មាអញគប្បីផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំដូច្នេះក៏ដោយ ក៏គង់តែចិត្តរបស់ភិក្ខុនោះ ផុតស្រឡះ

ចាកអាសវៈទាំងឡាយ ព្រោះតែមិនបានប្រកាន់មាំដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ត្រូវនិយាយថា ព្រោះតែភិក្ខុបានចំរើន ។ ព្រោះបានចំរើនអ្វី ។ ព្រោះតែបានចំរើនសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ក៏យ៉ាងនោះដែរ ។

ម្នាលភិក្ខុទាំងឡាយ ដូចជាងឈើ ឬកូនសិស្សរបស់ជាងឈើ យកម្រាមដៃនិងមេដើង ទៅចាប់កាន់ត្រង់មៀនកាំបិត ប៉ុន្តែជាងឈើ ឬកូនសិស្សរបស់ជាងឈើនោះមិនដឹងយ៉ាងនេះថា មៀនកាំបិតរបស់អញនោះ ថ្ងៃនេះសឹកអស់ប៉ុណ្ណោះ ឬថ្ងៃម្សិលសឹកអស់ប៉ុណ្ណោះ ឬក៏ម្សិលម្ង៉ៃ សឹកអស់ប៉ុណ្ណោះ ដូច្នេះទេ លុះដល់មៀនកាំបិតនោះសឹកអស់ហើយ ទើបបានដឹងថា អស់ហើយយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុប្រកបរឿយៗនូវភាវនា បើទុកជាមិនបានដឹងយ៉ាងនេះថា ថ្ងៃនេះអាសវៈទាំងឡាយរបស់អាត្មាអញអស់ទៅប៉ុណ្ណោះ ឬក៏ម្សិលម្ង៉ៃសឹកអស់ប៉ុណ្ណោះ ដូច្នេះទេ លុះអាសវៈនោះអស់ទៅ ទើបបានដឹងថា អស់ហើយ ក៏យ៉ាងនោះដែរ ។

ម្នាលភិក្ខុទាំងឡាយ ដូចជាសំពៅសមុទ្រដែលគេចងនឹងផ្តៅ ត្រាំនៅក្នុងទឹកអស់ ៦ ខែ ដល់ហេមន្តរដូវ គេលើកឡើងដាក់លើគោក ចំណងទាំងឡាយត្រូវខ្យល់និងកំដៅថ្ងៃ ចំណងទាំងនោះ ត្រូវភ្លៀងបង្អុរស្រោច ក៏ខូចពុកផុយបានដោយងាយ យ៉ាង

ណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុបានក្រុបក្រៀយៗនូវភាវនា សំយោជនៈទាំងឡាយ ក៏ស្ងប់រម្ងាប់បានដោយងាយ ក៏យ៉ាងនោះដែរ ។

## ចង្កមសូត្រ

នៅក្នុងព្រះត្រៃបិដកលេខ ៤៤ ទំព័រ ៥៦ ព្រះអង្គទ្រង់ត្រាស់សម្តែងអានិសង្សនៃការចង្ក្រម ៥ ប្រការ ជាមួយនឹងភិក្ខុទាំងឡាយថា៖

ម្នាលភិក្ខុទាំងឡាយ អានិសង្សក្នុងការចង្ក្រមនេះ មាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាងតើអ្វីខ្លះ ។

**១- អទ្ធានក្ខមោ ហោតិ** គឺជាអ្នកអត់ធន់ក្នុងដំណើរផ្លូវឆ្ងាយ

**២- បធានក្ខមោ ហោតិ** អត់ធន់ក្នុងការព្យាយាម

**៣- អប្បាពាធោ ហោតិ** មិនមានជម្ងឺ

៤- **អសិតំ បីតំ ខាទិតំ សាយិតំ សម្មាបរិណាមំ គច្ឆតិ** ភោជនដែលបរិភោគ ផឹក ទំពាស៊ី លិទ្ធិភ្លក្សហើយ រមែរលួយដោយស្រួល

**៥- ចង្កមាធិកតោ សមាធិ ចិរដ្ឋិតិកោ ហោតិ** សមាធិដែលកើតអំពីការចង្ក្រម រមែងតាំងនៅអស់កាលយូរ ១។

ម្នាលភិក្ខុទាំងឡាយ អានិសង្សក្នុងការចង្ក្រមមាន ៥ យ៉ាងនេះឯង ។

## អង្គសូត្រ

នៅក្នុងព្រះត្រៃបិដកលេខ ៤៤ ទំព័រ ១៣៣ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពី អង្គរបស់ភិក្ខុអ្នកមានសេចក្តីព្យាយាម ៥ ប្រការ មានសេចក្តីថា៖

ម្នាលភិក្ខុទាំងឡាយ អង្គនៃសេចក្តីព្យាយាមនេះមាន ៥ យ៉ាង ។ អង្គ ៥ តើដូចម្តេច ។

-ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធាជឿញាណគ្រឿងត្រាស់ដឹងរបស់ព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ជាអរហន្តជាសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជានិងចរណៈ ជាព្រះសុគតជ្រាបច្បាស់នូវលោក ជាបុគ្គលប្រសើរជាសារថីទូន្មាននូវបុរស ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ជាព្រះពុទ្ធលែងវិលមកកាន់ភពថ្មីទៀត ១។

-ជាអ្នកមិនមានអាពាធ មិនមានទុក្ខ ប្រកបដោយធាតុភ្លើងសម្រាប់ដុតកំដៅយ៉ាងល្មម មិនត្រជាក់ពេក មិនក្តៅពេក ជាយ៉ាងកណ្តាល គួរនឹងធ្វើព្យាយាម ១។

-ជាអ្នកមិនអួតអាង មិនមានមាយា ជាអ្នកធ្វើខ្លួនឱ្យប្រាកដតាមពិតក្នុងសំណាក់គ្រូ និងពួកសព្រហ្មចារីជាវិញ្ញូជន ១ ។

-ជាអ្នកប្រារព្ធព្យាយាមដើម្បីលះបង់អកុសលធម៌ ធ្វើកុសលធម៌ឱ្យសម្រេច មានកម្លាំងប្រឹងសង្វាត មិនដាក់ចុះនូវធុរៈ

ក្នុងកុសលធម៌ ១,

-ជាអ្នកមានបញ្ញាប្រកបដោយបញ្ញា អាចកំណត់នូវការកើត និងការរលត់ដ៏ប្រសើរ ជាគ្រឿងទំលុះទំលាយ(កិលេស) អាចកំណត់នូវធម៌ជាគ្រឿងអស់ទៅនៃទុក្ខដោយប្រពៃបាន ១។

ម្នាលភិក្ខុទាំងឡាយ អង្គនៃសេចក្តីព្យាយាមមាន ៥ នេះឯង។

## **រឿងបរិនិព្វានរបស់ព្រះគោធិកត្ថេរៈ**

ព្រះសាស្តា កាលស្តេចចូលទៅអាស្រ័យក្រុងរាជគ្រឹះ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធការបរិនិព្វានរបស់ព្រះគោធិកត្ថេរ ត្រាស់ធម្មទេសនានេះថា **តេសំ សម្បន្នសីលានំ** ជាដើម ។

### **ព្រះថេរៈគិតសម្លាប់ខ្លួនព្រោះសាបសូន្យចាកឈាន**

សេចក្តីពិស្តារថា ព្រះគោធិកៈដ៏មានអាយុនោះ នៅកាឡសិលាគុហាខាងភ្នំសិគិលិ ជាអ្នកមិនប្រមាទ មានព្យាយាមដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន បាននូវចេតោវិមុត្តិ ប្រកបតាមកាលវេលា, លំដាប់នោះឯង ព្រះគោធិកៈមានអាយុសាបសូន្យចាកចេតោវិមុត្តិ ដែលប្រកបតាមកាលវេលានោះ ដោយអំណាចនៃរោគមួយប្រភេទ ។ លោកញ៉ាំងឈានទី ២ ខ្វះ ទី ៣ ខ្វះ ឱ្យកើតឡើងដល់ ៦ ដង ហើយក៏សាបសូន្យចាកឈាននោះទៀតក្នុងវារៈទី ៧ ក៏ញ៉ាំងឈានឱ្យកើតឡើង ហើយបានគិតថា យើងសាបសូន្យចាកឈានដល់ ៦ ដងហើយ ក៏គិតរបស់អ្នក

មានឈានសាបសូន្យ មិនទៀងទាត់ទេ បើដូច្នោះ យើងនឹងនាំសស្រ្តាមក លុះគិតដូច្នោះហើយក៏កាន់កាំបិតសម្រាប់កោរសក់ដេកលើគ្រែតូច បំណងនឹងកាត់-ក ។

## មារទូលឱ្យព្រះសាស្តាទ្រង់ជ្រាប

គ្រានោះឯង មារមានចិត្តបាប ដឹងចិត្តរបស់ព្រះថេរៈហើយគិតថា ភិក្ខុនេះប្រាថ្នានឹងនាំសស្រ្តាមក,ក៏ភិក្ខុទាំងឡាយនាំសស្រ្តាមក រមែងជាអ្នកអស់សេចក្តីអាល័យក្នុងជីវិត, ភិក្ខុទាំងនោះផ្តើមតាំងវិបស្សនាហើយ រមែងបានសម្រេចអរហត្ត, បើនឹងហាមឃាត់ភិក្ខុនោះ លោកនឹងមិនធ្វើតាមពាក្យរបស់យើង, យើងនឹងទូលឱ្យព្រះសាស្តាហាមហើយ ដូច្នេះ ទើបចូលទៅគាល់ព្រះសាស្តា ដោយភេទដែលអ្នកដទៃមិនស្គាល់ ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គអ្នកមានព្យាយាមធំ មានប្រាជ្ញាច្រើន រុងរឿងដោយឫទ្ធិ និងយសកន្លងនូវពៀរ និងភ័យគ្រប់ប្រការ ទ្រង់មានចក្ខុ ខ្ញុំព្រះអង្គសូមថ្វាយបង្គំព្រះបាទា បពិត្រព្រះអង្គ អ្នកមានព្យាយាមធំសាវ័ករបស់ព្រះអង្គត្រូវសេចក្តីស្លាប់គ្របសង្កត់ ប្រាថ្នាគិតដល់សេចក្តីស្លាប់ បពិត្រព្រះអង្គ ទ្រទ្រង់នូវអានុភាព សូមព្រះអង្គឃាត់នូវសាវ័កនោះ បពិត្រព្រះមានព្រះភាគអ្នកល្បីក្នុងប្រជុំជនសាវ័ករបស់ព្រះអង្គជាសេក្ខបុគ្គល មានបំណងមិនទាន់សម្រេចនៅត្រេកអរក្នុងសាសនា គប្បីធ្វើមរណកាល ដូចម្តេចបាន ។

គ្រានោះឯង ព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់ថា បុគ្គលនេះជាមារមានចិត្តបាប ដូច្នេះហើយ ទើបពោលនឹងមារមានចិត្តបាបនោះដោយគាថាដូច្នេះថាៈ

ពិតមែន អ្នកប្រាជ្ញទាំងឡាយ តែងធ្វើយ៉ាងនេះឯង រមែងមិននឹកស្តាយនូវជីវិត គោធិកភិក្ខុបានដកតណ្ហា ព្រមទាំងឫសបរិនិព្វានហើយ ។

គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ មកយើងនឹងចូលទៅកាឡសិលា ជិតភ្នំសិគិលិ ត្បិតគោធិកកុលបុត្រយកកាំបិតមកហើយ ។ ពួកភិក្ខុបានទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ, ទើបព្រះមានព្រះភាគទ្រង់ចូលទៅកាន់កាឡសិលាខាងភ្នំសិគិលិ មួយអន្លើដោយពួកភិក្ខុច្រើនរូប ។ ព្រះមានព្រះភាគក៏បានឃើញគោធិកៈ មានអាយុកំពុងដេកផ្ងារផ្ងើយ-កលើគ្រែអំពីចម្ងាយលឹមៗ ។ សម័យនោះឯង ផ្សែងនិងអ័ព្ទក៏បក់ទៅកាន់ទិសខាងកើតខ្លះ បក់ទៅកាន់ទិសខាងលិចខ្លះ បក់ទៅកាន់ទិសខាងជើងខ្លះ បក់ទៅកាន់ទិសខាងត្បូងខ្លះ បក់ទៅកាន់ទិសខាងលើខ្លះ បក់ទៅកាន់ទិសខាងក្រោមខ្លះ បក់ទៅកាន់ទិសខាងខ្លះ ។

គ្រានោះឯង ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយ

ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញនូវផ្សែង និងអ័ព្ទនោះ បក់ទៅកាន់ទិសខាងលិចខ្លះ បក់ទៅកាន់ទិសខាងជើងខ្លះ បក់ទៅកាន់ទិសខាងត្បូងខ្លះ បក់ទៅកាន់ទិសខាងលើខ្លះ បក់ទៅកាន់ទិសខាងក្រោមខ្លះ បក់ទៅកាន់ទិសខាងតូចខ្លះឬទេ? ពួកភិក្ខុក្រាបបង្គំទូលថា ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយនោះឯងជាមារមានចិត្តបាប កំពុងស្វែងរកបដិសន្ធិវិញ្ញាណរបស់គោធិកកុលបុត្រថា វិញ្ញាណរបស់គោធិកកុលបុត្រឋិតនៅក្នុងទីណា ម្នាលភិក្ខុទាំងឡាយ គោធិកកុលបុត្រ មានវិញ្ញាណមិនបានឋិតនៅទេ បរិនិព្វានហើយ ។

គ្រានោះឯង មារមានចិត្តបាប យកពិណមានពណ៌លឿងដូចផ្លែព្នៅ ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ក៏ពោលនឹងព្រះមានព្រះភាគដោយគាថាដូច្នេះថា៖

ខ្ញុំព្រះអង្គបានស្វែងរក(វិញ្ញាណ) របស់គោធិកកុលបុត្រទិសខាងលើផង ខាងក្រោមផង ទិសទទឹងផង ទិសធំ ក្នុងទិសតូចផង មិនបានជួបប្រទះសោះឡើយ ចុះគោធិកៈនោះទៅក្នុងទីណា? ព្រះមានព្រះភាគត្រាស់ថា គោធិកៈជាអ្នកប្រាជ្ញ បរិបូណ៌ដោយប្រាជ្ញា ជាអ្នកមានឈាន អ្នកត្រេកអរក្នុងឈានសព្វកាលខំប្រឹងប្រែងទាំងថ្ងៃទាំងយប់ មិនគិតស្តាយជីវិត បានឈ្នះសេនារបស់មច្ចុ មិនមកកាន់ភពថ្មីទៀត ដកតណ្ហា ព្រមទាំងឫស

បរិនិព្វានហើយ ។ កាលមារនោះកំពុងត្រូវសោកគ្របសង្កត់ ពិណាក៏របូតចេញអំពីក្លៀក តពីនោះមកយក្សនោះ ក៏មានសេចក្ដីតូចចិត្តហើយ ក៏បាត់ចាកទីនោះទៅ ។

សូម្បីព្រះសាស្ដាទ្រង់ត្រាស់ថា មារមានចិត្តបាប អ្នកឯងត្រូវការអ្វីដោយស្ថានទី ដែលកុលបុត្រឈ្មោះគោធិកៈកើតហើយ, ព្រោះមនុស្សដូចអ្នកទាំងរយទាំងពាន់ ក៏មិនអាចនឹងឃើញទីដែលគោធិកៈនោះកើតដែរ ដូច្នេះហើយ បានត្រាស់ព្រះគាថានេះថា៖

តេសំ សម្បន្នសីលានំ អប្បមាទវិហារិនំ
សម្មទញ្ញា វិមុត្តានំ មារោ មគ្គំ ន វិន្ទតិ។

មារាធិរាជ ទុកជាខំស្វែងរក ក៏មិនជួបនូវផ្លូវរបស់លោកអ្នកមានសីលបរិបូណ៌ អ្នកនៅដោយសេចក្ដីមិនប្រមាទ អ្នករួចស្រឡះចាកធម៌ជាគ្រឿងសៅហ្មង ព្រោះដឹងច្បាស់តាមហេតុ ។

**អធិប្បាយគាថា**

បណ្ដាបទទាំងនោះ **បទថា តេសំ** គឺនៃអ្នកដែលបរិនិព្វានដូចជាកុលបុត្រឈ្មោះគោធិកៈមានវិញ្ញាណមិនតាំងនៅបរិនិព្វានហើយដូច្នោះ ។

បទថា **សម្បន្នសីលានំ** គឺអ្នកមានសីលបរិបូណ៌ហើយ ។

បទថា **អប្បមាទវិហារិនំ** គឺអ្នកនៅដោយសេចក្ដីមិនប្រមាទ

ពោល គឺមិនប្រាសចាកសតិ ។

បាទព្រះគាថាថា **សម្មទញ្ញា វិមុត្តានំ** សេចក្ដីថា អ្នករួចផុតពិសេសហើយ ដោយវិមុត្តិ ៥ យ៉ាង គឺ(តទង្គវិមុត្តិ វិក្ខម្ភនវិមុត្តិ សមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និស្សរណវិមុត្តិ) ព្រោះដឹងដោយហេតុ គឺដោយន័យ ដោយការណ៍ ។

បាទព្រះគាថាថា **មារោ មគ្គំ ន វិន្ទតិ** សេចក្ដីថា មារាធិរាជសូម្បីស្វែងរកដោយពេញកម្លាំង ក៏រមែងមិនជួបគឺ រមែងមិនបានចំពោះ បានដល់ រមែងមិនឃើញផ្លូវរបស់ព្រះខីណាស្រពទាំងឡាយ បែបនេះធ្វើដំណើរទៅហើយ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ទេសនាបានមានជាប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

## ឧដ្ឋានសូត្រ

នៅក្នុងព្រះត្រៃបិដកលេខ ៥៤ ទំព័រ ១០៦ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ដាស់តឿនភិក្ខុទាំងឡាយកុំឱ្យមានសេចក្ដីប្រមាទ មានសេចក្ដីថា៖

អ្នកទាំងឡាយចូរក្រោក (ចូរអង្គុយចម្រើនកម្មដ្ឋាន) ប្រយោជន៍អ្វី ដោយការដេកលក់របស់អ្នកទាំងឡាយ ព្រោះថាអ្នកទាំងឡាយឈឺជានិច្ច ត្រូវសរគឺរាគាទិក្កិលេសចាក់ដោតហើយ

កំពុងតែលំបាក ម្ដេចក៏នៅដេកលក់ ។

អ្នកទាំងឡាយចូរក្រោកអង្គុយ ចូរសិក្សាឱ្យមាំមួនដើម្បីសេចក្ដីស្ងប់ កុំឱ្យមច្ចុរាជបានដឹងនូវអ្នកទាំងឡាយថា ជាអ្នកប្រមាទ ហើយធ្វើឱ្យវង្វេង លុះក្នុងអំណាចនៃខ្លួនឡើយ ។

ពួកទេវតានិងមនុស្ស ត្រូវការនឹងអារម្មណ៍ជាដើមអាស្រ័យជាប់នៅ(ក្នុងអារម្មណ៍) ព្រោះតណ្ហាណា អ្នកទាំងឡាយចូរឆ្លងនូវតណ្ហាជាគ្រឿងផ្សាយនុំះ កុំឱ្យខណៈកន្លងផុតនូវអ្នកទាំង ឡាយឡើយ ព្រោះថា ពួកជនដែលខណៈកន្លងហើយរមែងសោកសៅណែនណាន់ក្នុងនរក ។

សេចកីប្រមាទជាធូលី ធូលីធ្លាក់ចុះតាមសេចក្ដីប្រមាទ ព្រោះតែសេចក្ដីប្រមាទ កុលបុត្រដកចោលនូវសរ គឺរាគាទិក្កិ-លេសរបស់ខ្លួនបាន ដោយវិជ្ជាគឺអាសវក្ខយញ្ញាណ ព្រោះតែសេចក្ដីមិនប្រមាទ ។

## សំវរសូត្រ

នៅក្នុងព្រះត្រៃបិដកលេខ ៤២ ទំព័រ ៣៨ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ អំពីសេចក្ដីព្យាយាម ៤ យ៉ាង គឺ៖

ម្នាលភិក្ខុទាំងឡាយ បធាន (សេចក្ដីព្យាយាម)នេះ មាន ៤ យ៉ាង ។ បធានទាំង ៤ យ៉ាង តើដូចម្ដេច ។ គឺសំវរប្បធាន ១ បហានប្បធាន ១ ភាវនាប្បធាន ១ អនុរក្ខនាបធាន ១។

ម្នាលភិក្ខុទាំងឡាយ **សំវរប្បធាន** តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយភ្នែកហើយ មិនបានកាន់យកនូវនិមិត្ត មិនបានកាន់យកនូវអនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវបុគ្គលដែលមិនបានសង្រួមនូវចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួមនូវចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយ ដល់នូវសេចក្ដីសង្រួមក្នុងចក្ខុន្ទ្រិយ ឮសម្លេងដោយត្រចៀក... ធុំក្លិនដោយច្រមុះ... ជញ្ជក់រសដោយអណ្ដាត ពាល់ត្រូវនូវផ្សព្វដោយកាយ...ដឹងនូវធម្មារម្មណ៍ដោយចិត្ត មិនបានកាន់យកនូវនិមិត្ត មិនបានកាន់យកនូវអនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវបុគ្គលដែលមិនបានសង្រួមនូវមនិន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួមនូវចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវមនិន្ទ្រិយនោះ រក្សានូវមនិន្ទ្រិយដល់នូវសេចក្ដីសង្រួមក្នុងមនិន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **សំវរប្បធាន** ។

ម្នាលភិក្ខុទាំងឡាយ **បហានប្បធាន** តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនបានតាំងចិត្តទទួល ខំលះបង់ បន្ទោបង់ ធ្វើឱ្យអស់ទៅ ឱ្យដល់នូវសេចក្ដីវិនាសនូវកាម-វិតក្កៈ ដែលកើតឡើងហើយ ព្យាបាទវិតក្កៈ ដែលកើតឡើង

ហើយ... វិហឹសាវិតក្កៈដែលកើតឡើងហើយ... មិនបានតាំងចិត្តទទួល ខំលះបង់ បន្ទោបង់ ធ្វើឱ្យអស់ទៅ ឱ្យដល់នូវសេចក្តីវិនាសនូវអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ កើតឡើងហើយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **បហានប្បធាន** ។

ម្នាលភិក្ខុទាំងឡាយ **ភាវនាប្បធាន** តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្តីស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័នូវសេចក្តីរលត់ មានកិរិយាបង្អោនទៅដើម្បីលះបង់ ចំរើននូវធម្មវិចយសម្ពោជ្ឈង្គ... ចំរើននូវវីរិយសម្ពោជ្ឈង្គ... ចំរើននូវបីតិ-សម្ពោជ្ឈង្គ... ចំរើននូវបស្សទ្ធិសម្ពោជ្ឈង្គៈ... ចំរើននូវសមាធិ-សម្ពោជ្ឈង្គៈ... ចំរើននូវឧបេក្ខាសម្ពោជ្ឈង្គ...ចំរើននូវសម្ពោជ្ឈង្គៈ... ដែលអាស្រ័យនូវសេចក្តីស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័នូវសេចក្តីរលត់ មានកិរិយាបង្អោនទៅដើម្បីលះបង់ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **ភាវនាប្បធាន** ។

ម្នាលភិក្ខុទាំងឡាយ **អនុរក្ខនាបធាន** តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រក្សាទុកនូវសមាធិនិមិត្ត គឺអដ្ឋិកសញ្ញា បុឡវកសញ្ញា វិនីលកសញ្ញា វិបុព្វកសញ្ញា វិច្ឆិទ្ទក-សញ្ញា ឧទ្ធុមាតកសញ្ញាដ៏ល្អ ដែលកើតឡើងហើយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **អនុរក្ខនាបធាន** ។

**សំវរោ ច បហានញ្ច ភាវនា អនុរក្ខនា**
**ឯតេ បធានា ចត្តារោ ទេសិតាទិច្ចពន្ធុនា**
**យេហិ ភិក្ខុ ឥធាតាបី ខយំ ទុក្ខស្ស បាបុណេតិ។**

*សំវរប្បធាន ១ បហានប្បធាន ១ ភាវនាបធាន ១ អនុរក្ខនា-បធាន ១ បធានទាំង ៤ យ៉ាងនេះ ព្រះពុទ្ធជាផៅពង្សនៃព្រះអាទិត្យទ្រង់សំដែងហើយ ដែលភិក្ខុក្នុងសាសនានេះ មានព្យាយាមដុតកំដៅកិលេស បានដល់នូវអរហត្ត ជាធម៌អស់ទៅនៃទុក្ខ ។*

**អដ្ឋកថា**

***សេចក្តីព្យាយាម*** *ឈ្មោះ បធាន ។ សេចក្តីព្យាយាមដែលកើតឡើងដល់អ្នកសង្រួមចក្ខុជាដើមឈ្មោះ សំវរបធាន ។ សេចក្តីព្យាយាម ដែលកើតឡើងដល់អ្នកលះកាមវិតក្កជាដើម ឈ្មោះ បហានបធាន ។*

*សេចក្តីព្យាយាមដែលកើតឡើងដល់អ្នកចម្រើន សម្ពោជ្ឈង្គ ឈ្មោះថា ភាវនាបធាន ។*

*សេចក្តីព្យាយាម ដែលកើតឡើងដល់ភិក្ខុដែលតាមរក្សាសមាធិនិមិត្ត ឈ្មោះថា អនុរក្ខនាបធាន ។*

*ក្នុងបទថា* ***វិវេកនិស្សិតំ ជាអាទិ*** *មានវិនិច្ឆ័យដូច្នេះ សូម្បីបទទាំង ៣ គឺ វិវេក វិរាគៈ និរោធជាឈ្មោះរបស់និព្វាន ។ ពិតមែននិព្វានឈ្មោះ វិវេក ព្រោះស្ងប់ចាកពីឧបធិ ឈ្មោះ វិរាគៈ ព្រោះរាគៈជាដើម អាស្រ័យនិព្វាននោះ ទើបបំបាត់ទៅ ។ ឈ្មោះ*

និរោធ ព្រោះរាគៈជាដើម អាស្រ័យនិព្វាននោះ ក៏រលត់ទៅ ព្រោះដូច្នោះ ក្នុងបទថា **វិវេកនិស្សិតំ ជាអាទិ** ទើបមានសេចក្ដីថា អាស្រ័យនិព្វានដោយជាអារម្មណ៍ខ្លះ ជាធម៌ដែលគប្បីសម្រេចខ្លះ ។

ក្នុងបទថា **វោស្សគ្គបរិណាមឹ** នេះ វោសសគ្គៈមាន ២ គឺ បរិច្ចាគវោសសគ្គៈ ១ បក្ខន្ទនវោសសគ្គៈ ១ ។ ក្នុងពីរយ៉ាងនោះ វិបស្សនាឈ្មោះបរិច្ចាគវោសសគ្គៈ ព្រោះលះបង់រាគៈក្នុងកិលេស និងខន្ធ ដោយអំណាចតទង្គបហាន មគ្គ ឈ្មោះបក្ខន្ទនវោសសគ្គៈ ព្រោះត្រាច់ទៅកាន់និព្វានដោយអំណាចអារម្មណ៍ ។ ព្រោះដូច្នោះ ក្នុងបទថា **វោស្សគ្គបរិណាមឹ** នេះ ទើបសេចក្ដីដូច្នេះថា សតិសម្ពោជ្ឈង្គ ដែលភិក្ខុចម្រើននៅដោយប្រការណា រមែងបង្អោនទៅដើម្បីលះបង់ រមែងដល់វិបស្សនាភាវនា និងមគ្គភាវនា ភិក្ខុរមែងចម្រើនសតិសម្ពោជ្ឈង្គនោះ ដោយប្រការនោះ សូម្បីក្នុងបទដែលនៅសល់ក៏ន័យនេះឯង ។

បទថា **ភទ្ទកំ** បានដល់ ដែលបានហើយ ។ សមាធិដែលបានហើយ ដោយអំណាចអដ្ឋិកសញ្ញាជាដើម ហៅថា សមាធិនិមិត្ត ។

បទថា **អនុរក្ខតិ** បានដល់ ធ្វើរាគៈ ទោសៈ មោហៈ ដែលជាធម៌ ជាសត្រូវចំពោះសមាធិឱ្យស្ងួតហួតហែងទៅរក្សាទុក ។ ក៏

សញ្ញា ៩ មានអដ្ឋកិសញ្ញាជាដើម ត្រាស់ទុកក្នុងសេចក្ដីនេះតែក្នុងទីនេះ គប្បីពោលអសុភសញ្ញា ១០ ឱ្យពិស្ដារផង ។ សេចក្ដីពិស្ដាររបស់អសុភសញ្ញានោះ ពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។

ក្នុងគាថា លោកពោលសេចក្ដីព្យាយាមតែម៉្យាងដែលឱ្យសម្រេចសំវរៈជាដើម ដោយឈ្មោះថា សំវរៈ ។

បទថា **ខយំ ទុក្ខស្ស បាបុណេ** គឺគប្បីសម្រេចព្រះអរហត្ត ពោល គឺធម៌ជាទីអស់ទុក្ខ ។

## បធានសូត្រ

នៅក្នុងព្រះត្រៃបិដកលេខ ៤២ ទំព័រ ៣៧ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ អំពីសម្មប្បធាន ៤ យ៉ាង គឺ៖

ម្នាលភិក្ខុទាំងឡាយ **សម្មប្បធាន** (សេចក្ដីព្យាយាមប្រពៃ) នេះ មាន ៤ យ៉ាង ។ សម្មប្បធាន ៤ យ៉ាង តើដូចម្ដេច ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញុាំងឆន្ទៈឱ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុាំងអកុសលធម៌ដ៏លាមក ដែលមិនទាន់កើតឡើង មិន ឱ្យកើតឡើងបាន ១។

(ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ) ញុាំងឆន្ទៈឱ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីលះបង់នូវអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ១។

(ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ) ញុំាងឆន្ទៈឱ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងកុសលធម៌ដែលកើតឡើង ឱ្យកើតឡើង ១។

(ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ) ញុំាងឆន្ទៈឱ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងកុសលធម៌ដែលកើតឡើងហើយឱ្យស្ថិតនៅ មិនឱ្យភ្លេចភ្លាំងទៅ ឱ្យចំរើនធំទូលាយ បរិបូណ៌ក្រៃលែងឡើង ១។

ម្នាលភិក្ខុទាំងឡាយ សម្មប្បធាន មាន ៤ យ៉ាងប៉ុណ្ណេះ ។

**សម្មប្បធានា មារធេយ្យាភិភូតា ចារគូ**

**តេ អសិតា ជាតិមរណភយស្ស ចារគូ**

**តេ តុសិតា ជេត្វា ន មារំ សវាហនំ**

**តេ អនេជា (សព្វំ) នមុចិពលំ**

**ឧបាតិវត្តា (តេ សុខិតាតិ)។**

ព្រះខីណាស្រពទាំងនោះ ជាអ្នកមានព្យាយាមដោយប្រពៃ គ្របសង្កត់នូវមារគឺវដ្តៈបាន ជាអ្នកមិនបានអាស្រ័យ ជាអ្នកដល់ត្រើយនៃភ័យ គឺជាតិ និងមរណៈ ត្រេកអរបានឈ្នះនូវមារព្រមទាំងវាហនៈ គឺសេនារបស់មារ ព្រះខីណាស្រពនោះមិនបានញាប់ញ័រដោយតណ្ហា កន្លងបង់នូវពលនៃមារទាំងអស់បាន (លោកដល់នូវសេចក្តីសុខឡើយ) ។

## អដ្ឋកថា

បទថា **សម្មប្បធានានិ** បានដល់ សេចក្តីព្យាយាមល្អ គឺសេចក្តីព្យាយាមខ្ពស់បំផុត ។

បទថា **សម្មប្បធានា** បានដល់ ព្រះខីណាស្រពអ្នកមានសេចក្តីព្យាយាមបរិបូរណ៌ ។

បទថា **មារធេយ្យាភិភូតា** សេចក្តីថា ព្រះខីណាស្រពទាំងនោះ គ្របសង្កត់ឆ្លងដែនមារ គឺតេភូមិកវដ្ត ។

បទថា **តេ អសិតា** បានដល់ ព្រះខីណាសីពទាំងឡាយជាអ្នកដែលកិលេសមិនអាស្រ័យហើយ ។

បទថា **ជាតិមរណភយស្ស** បានដល់ ភ័យដែលកើតឡើងព្រោះអាស្រ័យការកើតនិងសេចក្តីស្លាប់ ឬភ័យពោលគឺការកើតនិងសេចក្តីស្លាប់ ។

បទថា **បារគូ** ប្រែថា ដល់ត្រើយ ។

បទថា **តេ តុសិតា** សេចក្តីថា ព្រះខីណាស្រពទាំងនោះឈ្មោះថា ត្រេកអរហើយ ។

បទថា **ជេត្វា មារំ សវាហនំ** បានដល់ ឈ្នះមារ និងទាំងកងទ័ពនៅហើយ ។

បទថា **តេ អនេជា** សេចក្តីថា ព្រះខីណាស្រពទាំងនោះមិនខ្វាច ស្ញូន់ស្ញោដោយសេចក្តីខ្វាចស្ញូន់ស្ញោគឺ តណ្ហា ឈ្មោះថាមិនញាប់ញ័រ ។

បទថា **ន មុចិពលំ** ប្រែថា ពលរបស់មារ ។

បទថា **ឧបាតិវត្តា** ប្រែថា ឈានកន្លង ។

បទថា **តេ សុខិតា** បានដល់ ព្រះខីណាស្រពទាំងនោះឈ្មោះថា មានសេចក្ដីសុខដោយលោកុត្តរសុខ ។ ដោយហេតុនោះ លោកទើបពោលថា ព្រះអរហន្តទាំងឡាយសុខពិតហ្ន៎ លោកមិនមានតណ្ហា ដកអស្មិមានះបានដាច់ខាតហើយ ទម្លាយសំណាញ់គឺ មោហៈចេញហើយ ដូច្នេះ ។

## ចារសូត្រ

នៅក្នុងព្រះត្រៃបិដកលេខ ៤២ ទំព័រ ៣១ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់អំពីភិក្ខុមិនលះបង់កាមវិតក្កៈ ៣ យ៉ាង គឺ

ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកាមវិតក្កៈក្ដី ព្យាបាទវិតក្កៈក្ដី វិហឹសាវិតក្កៈក្ដី កើតឡើងដល់ភិក្ខុកំពុងដើរទៅ បើភិក្ខុតាំងចិត្តទទួល មិនលះបង់ មិនបន្ទោបង់ មិនធ្វើឱ្យអស់ទៅ មិនឱ្យដល់នូវសេចក្ដីវិនាសនូវវិតក្កៈទាំងនោះទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលដើរទៅ មានសភាពយ៉ាងនេះ ហៅថា មិនមានព្យាយាមដុតកំដៅកិលេស មិនខ្លាចពាក្យតិះដៀល ខ្ជិលច្រអូស មានព្យាយាមថោកថយ ជានិច្ចនិរន្ដ ។

ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកាមវិតក្កៈក្ដី ព្យាបាទវិតក្កៈក្ដី វិហឹសាវិតក្កៈក្ដី កើតឡើងដល់ភិក្ខុកំពុងឈរ បើភិក្ខុតាំងចិត្ត

ទទួល មិនលះបង់ មិនបន្ទោបង់ មិនធ្វើឱ្យអស់ទៅ មិនឱ្យដល់នូវសេចក្តីវិនាសនូវវិតក្កៈទាំងនោះទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលឈរ មានសភាពយ៉ាងនេះ ហៅថា មិនមានព្យាយាមដុតកំដៅកិលេស មិនខ្លាចពាក្យតិះដៀល ខ្ជិលច្រអូស មានព្យាយាមថោកថយ ជានិច្ចនិរន្ត ។

ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកាមវិតក្កៈក្តី ព្យាបាទវិតក្កៈក្តី វិហឹសាវិតក្កៈក្តី កើតឡើងដល់ភិក្ខុដែលកំពុងអង្គុយ បើភិក្ខុតាំងចិត្តទទួល មិនលះបង់ មិនបន្ទោបង់ មិនធ្វើឱ្យអស់ទៅ មិនឱ្យដល់នូវសេចក្តីវិនាសនូវវិតក្កៈទាំងនោះទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលអង្គុយ មានសភាពយ៉ាងនេះ ហៅថា មិនមានព្យាយាមដុតកំដៅកិលេស មិនខ្លាចពាក្យតិះដៀល ខ្ជិលច្រអូស មានព្យាយាមថោកថយ ជានិច្ចនិរន្ត ។

ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកាមវិតក្កៈក្តី ព្យាបាទវិតក្កៈក្តី វិហឹសាវិតក្កៈក្តី កើតឡើងដល់ភិក្ខុកំពុងដេក កំពុងភ្ញាក់រលឹក បើភិក្ខុតាំងចិត្តទទួល មិនលះបង់ មិនបន្ទោបង់ មិនធ្វើឱ្យអស់ទៅ មិនឱ្យដល់នូវសេចក្តីវិនាសនូវវិតក្កៈទាំងនោះទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលដេក ភ្ញាក់រលឹកមានសភាពយ៉ាងនេះ ហៅថា មិនមានព្យាយាមដុតកំដៅកិលេស មិនខ្លាចពាក្យតិះដៀល ខ្ជិលច្រអូស មានព្យាយាមថោកថយ ជានិច្ចនិរន្ត ។

ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកាមវិតក្កៈក្តី ព្យាបាទវិតក្កៈក្តី វិហឹសាវិតក្កៈក្តី កើតឡើងដល់ភិក្ខុកំពុងដើរ បើភិក្ខុមិនបានតាំងចិត្តទទួល ខំលះបង់ បន្ទោបង់ចេញ ធ្វើឱ្យអស់ទៅ ឱ្យដល់នូវសេចក្តីវិនាសនូវវិតក្កៈទាំងនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលដើរទៅ មានសភាពយ៉ាងនេះ ហៅថា មានព្យាយាមដុតកំដៅកិលេស មានសេចក្តីខ្លាចពាក្យតិះដៀល មានព្យាយាមប្រារព្ធហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ជានិច្ចនិរន្ត ។

ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកាមវិតក្កៈក្តី ព្យាបាទវិតក្កៈក្តី វិហឹសាវិតក្កៈក្តី កើតឡើងដល់ភិក្ខុកំពុងឈរ បើភិក្ខុមិនបានតាំងចិត្តទទួល ខំលះបង់ បន្ទោបង់ចេញ ធ្វើឱ្យអស់ទៅ ឱ្យដល់នូវសេចក្តីវិនាសនូវវិតក្កៈទាំងនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលឈរ មានសភាពយ៉ាងនេះ ហៅថា មានព្យាយាមដុតកំដៅកិលេស មានសេចក្តីខ្លាចពាក្យតិះដៀល មានព្យាយាមប្រារព្ធហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ជានិច្ចនិរន្ត ។

ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកាមវិតក្កៈក្តី ព្យាបាទវិតក្កៈក្តី វិហឹសាវិតក្កៈក្តី កើតឡើងដល់ភិក្ខុកំពុងអង្គុយ បើភិក្ខុមិនបានតាំងចិត្តទទួល ខំលះបង់ បន្ទោបង់ចេញ ធ្វើឱ្យអស់ទៅ ឱ្យដល់នូវសេចក្តីវិនាសនូវវិតក្កៈទាំងនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអង្គុយមានសភាពយ៉ាងនេះ ហៅថា មានព្យាយាមដុតកំដៅ

*កិលេស មានសេចក្ដីខ្លាចពាក្យតិះដៀល មានព្យាយាម ប្រារព្ធហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ជានិច្ចនិរន្តរ៍ ។*

*ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកាមវិតក្កៈក្ដី ព្យាបាទវិតក្កៈក្ដី វិហឹសាវិតក្កៈក្ដី កើតឡើងដល់ភិក្ខុកំពុងដេក កំពុងភ្ញាក់រលឹក បើភិក្ខុមិនបានតាំងចិត្តទទួល ខំលះបង់ បន្ទោបង់ចេញ ធ្វើឱ្យអស់ទៅ ឱ្យដល់នូវសេចក្ដីវិនាសនូវវិតក្កៈទាំងនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលដេក ភ្ញាក់រលឹកមានសភាពយ៉ាងនេះ ហៅថា មានព្យាយាមដុតកំដៅកិលេស មានសេចក្ដីខ្លាចពាក្យតិះដៀល មានព្យាយាមប្រារព្ធហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ជានិច្ចនិរន្តរ៍ ។*

ចរំ វា យទិ វា តិដ្ឋំ និសិន្នោ ឧទ វា សយំ
យោ វិតក្កំ វិតក្កេតិ បាបកំ គេហនិស្សិតំ
កុម្មគ្គំ បដិបន្នោ សោ មោហនេយ្យេសុ មុច្ឆិតោ
អភព្វោ តាទិសោ ភិក្ខុ ផុដ្ឋុំ សម្ពោធិមុត្តមំ។
យោ ចរំ វាបិ តិដ្ឋំ វា និសិន្នោ ឧទ វា សយំ
វិតក្កំ សមយិត្វាន វិតក្កូបសមេ រតោ
ភព្វោ សោ តាទិសោ ភិក្ខុ ផុដ្ឋុំ សម្ពោធិមុត្តមន្តិ។

*ភិក្ខុណា កាលដើរក្ដី ឈរក្ដី អង្គុយក្ដី ដេកក្ដី តែងត្រិះរិះនូវវិតក្កៈ ដែលអាស្រ័យនូវផ្ទះគឺកិលេសដ៏លាមក ភិក្ខុប្រាកដដូច្នោះ*

នោះ ឈ្មោះថា ដើរទៅផ្លូវដែលបណ្ឌិតគប្បីខ្ពើម ជ្រប់នៅក្នុងអារម្មណ៍ ជាគ្រឿងវង្វេង មិនអាចពាល់ត្រូវនូវញាណ ជាគ្រឿងត្រាស់ដឹងដ៏ឧត្តមទេ ។ ភិក្ខុណាកាលដើរក្តី ឈរក្តី អង្គុយក្តី ដេកក្តី បានរម្ងាប់នូវកាមវិតក្កៈ ត្រេកអរក្នុងធម៌ ជាគ្រឿងរម្ងាប់នូវវិតក្កៈ ភិក្ខុប្រាកដដូច្នោះនោះ ទើបអាចពាល់ត្រូវនូវញាណ ជាគ្រឿងត្រាស់ដឹងដ៏ឧត្តមបាន ។

## អដ្ឋកថា

បទថា **អធិវាសេតិ** បានដល់ លើកឡើងទុកឱ្យនៅក្នុងចិត្ត (គឺសម្រាកទុក)។

បទថា **ន បជហាតិ** បានដល់ មិនលះបង់ ។

បទថា **ន វិនោទេតិ** បានដល់ មិននាំចេញ ។

បទថា **ន ព្យន្តីករោតិ** បានដល់ មិនធ្វើឱ្យដល់ទីបំផុត គឺកាត់ផ្លូវ ។

បទថា **ន អនភាវំ គមេតិ** បានដល់ មិនធ្វើឱ្យដល់សេចក្តីមិនមាន មិនច្រើន គឺអស់ទៅ ។

បទថា **ចរម្បិ** គឺ សូម្បីដើរ ។

បទថា **អនាតាបិ** គឺ មិនមានសេចក្តីព្យាយាម ។

បទថា **អនោត្តាបិ** គឺវៀរចាកសេចក្តីខ្លាច ការតិះដៀលតិ ។

បទថា **សតតំ** គឺ ជានិច្ច ។

បទថា **សមិតំ** គឺ មិនមានចន្លោះ ។ អ្នកសិក្សាជ្រាបសេចក្តីក្នុងគ្រប់បទយ៉ាងនេះហើយ គប្បីជ្រាបសេចក្តីតាមបរិយាយដែលពោលទុកហើយក្នុងសុក្កបក្ខ ។

ក្នុងគាថា គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

បទថា **គេហនិស្សិតំ** បានដល់ អាស្រ័យកិលេស ។

បទថា **មោហនេយ្យេសុ** បានដល់ ក្នុងអារម្មណ៍ដែលឱ្យកើតសេចក្តីវង្វេង ។

បទថា **អកញ្ចោ** បានដល់ មិនដូចជាភាជនៈដែលទ្រទទួល។

បទថា **ផុដ្ឋំ សម្ពោធិមុត្តមំ** បានដល់ ដើម្បីសម្ពស្សឧតមាណ ពោលគឺ ព្រះអរហត្ត ។

## សីលសូត្រ

នៅក្នុងព្រះត្រៃបិដកលេខ ៤២ ទំព័រ ៣៥ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ អំពីបរិសុទ្ធិសីល ៤ យ៉ាង គឺ៖

ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយ បរិបូណ៌ដោយសីល បរិបូណ៌ដោយបាតិមោក្ខ សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈ និងគោរចៈឃើញភ័យក្នុងទោស សូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ បរិបូណ៌ដោយសីល បរិបូណ៌ដោយបាតិមោក្ខ សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈ

និងគោរចៈឃើញភ័យក្នុងទោស សូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ តើគប្បីមានកិច្ចអ្វីដែលគួរធ្វើឱ្យក្រៃលែងឡើងទៀត ។

ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុកាលដើរមានអភិជ្ឈា... មានព្យាបាទទៅប្រាសហើយ មានសេចក្ដីងងុយនឹងងោកងក់... មានសេចក្ដីរវើរវាយនឹងសេចក្ដីរំខានចិត្ត... មានសេចក្ដីសង្ស័យលះបង់ហើយ មានព្យាយាមប្រារព្ធហើយ មិនបានរួញរា មានស្មារតីប្រុងខ្ជាប់ មិនបានវង្វេងភ្លេច មានកាយស្ងប់រម្ងាប់ មិនបានក្រវល់ក្រវាយ មានចិត្តដំកល់មាំនៅក្នុងអារម្មណ៍តែមួយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលដើរមានសភាពយ៉ាងនេះហៅថា មានព្យាយាមដុតកំដៅកិលេស មានសេចក្ដីខ្លាចពាក្យតិះដៀល មានព្យាយាមប្រារព្ធហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានជានិច្ចនិរន្ត ។

ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុកាលឈរ..., ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុកាលអង្គុយ..., ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុកំពុងដេក កំពុងភ្ញាក់រលឹក..., មានអភិជ្ឈា..., មានព្យាបាទទៅប្រាសហើយ មានសេចក្ដីងងុយនឹងងោកងក់... មានសេចក្ដីរវើរវាយនឹងសេចក្ដីរំខានចិត្ត... មានសេចក្ដីសង្ស័យលះបង់ហើយ មានព្យាយាមប្រារព្ធហើយ មិនបានរួញរា មានស្មារតី

ប្រុងខ្ជាប់ មិនបានវង្វេងភ្លេច មានកាយស្ងប់រម្ងាប់ មិនបានក្រវល់ក្រវាយ មានចិត្តដំកល់មាំនៅក្នុងអារម្មណ៍តែមួយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលដេកភ្ញាក់រលឹកមានសភាពយ៉ាងនេះហៅថា មានព្យាយាមដុតកំដៅកិលេស មានសេចក្ដីខ្លាចពាក្យតិះដៀល មានព្យាយាម ប្រារព្ធហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានជានិច្ចនិរន្តរ៍ ។

តយញ្ចារ យតំ តិដ្ឋេ យតំ អច្ឆេ យតំ សយេ
យតំ សម្មិញ្ជោយ ភិក្ខុ យតមេតំ បសារយេ
ឧទ្ធំ តិរិយំ អបាចីនំ យាវតា ជគតោ គតិ
សមវេក្ខិតា ច ធម្មានំ ខន្ធានំ ឧទយព្វយំ
ចេតោសមថសាមីចឹ សិក្ខមានំ សទាសតឹ
សតតំ បហិតត្តោតិ អាហុ ភិក្ខុំ តថាវិធន្តិ។

ភិក្ខុគប្បីដើរ សង្រួម គប្បីឈរ សង្រួម គប្បីអង្គុយ សង្រួម គប្បីដេក សង្រួម គប្បីបត់(នូវអវយវៈតូចធំ)សង្រួម គប្បីលាតនូវអវយវៈតូចធំនុ៎ះ សង្រួម គតិនៃសត្វលោកទាំងខាងលើ កណ្ដាល និងខាងក្រោម មានកំណត់ត្រឹមណា អ្នកប្រាជ្ញពិចារណាឃើញនូវកិរិយាកើតឡើង និងវិនាសទៅនៃធម៌ គឺខន្ធទាំងឡាយ មានកំណត់ត្រឹមណោះ ទើបពោលថា ភិក្ខុមានសភាពដូច្នោះ ជាអ្នកសិក្សានូវបដិបទាដ៏សមគួរ ដល់នូវសេចក្ដីស្ងប់រម្ងាប់ចិត្ត មានសតិ

សព្វកាល ឈ្មោះថា ជាអ្នកមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ជានិច្ច ។

## អដ្ឋកថា

បទថា **សម្បន្នសីលា** បានដល់ លោកទាំងឡាយមានសីល បរិបូរណ៌ ។

បទថា**សម្បន្នបាតិមោក្ខា** បានដល់ មានបាតិមោក្ខបរិបូរណ៌។

បទថា **បាតិមោក្ខសំវរសំវុតា** សេចក្ដីថា លោកទាំងឡាយ ចូរជាអ្នកសង្រួមប្រកបដោយបាតិមោក្ខសំវរសីលនៅចុះ ។

បទថា **អាចារគោចរសម្បន្នា** ។ សេចក្ដីថា លោកទាំងឡាយ ចូរជាអ្នកដល់ព្រម គឺប្រកបដោយអំណាចារៈនិងគោចរចុះ ។

បទថា **អណុមត្តេសុ វជ្ជេសុ** បានដល់ ក្នុងទោសទាំង ឡាយមានប្រមាណតិច ។

បទថា **ភយទស្សាវិនោ** សេចក្ដីថា ជាអ្នកមានប្រក្រតី ឃើញទោស ដែលមានប្រមាណតិច ពួកនេះដោយជាភ័យ ។

បទថា **សមាទាយសិក្ខថ សិក្ខាបទេសុ** សេចក្ដីថា លោក ទាំងឡាយ ចូរសមាទានប្រកាន់សិក្ខាបទ ដែលគួរសមាទាន នោះៗ ក្នុងចំណែកនៃសិក្ខាទាំងអស់សិក្សា ។ គ្រាទ្រង់ត្រាស់ សរសើរក្នុងគុណដែលបានហើយ ដោយការត្រាស់ធម៌ប្រមាណ ប៉ុណ្ណោះថា **សម្បន្នាសីលានំ** ។បេ។ **សិក្ខាបទេសុ** ឥឡូវនេះ កាល

ទ្រង់សម្ដែងប្រយោជន៍ ដែលនឹងគប្បីធ្វើឱ្យក្រៃលែងឡើងទៅ ទើបត្រាស់ថា **កិមស្ស** ដូច្នេះជាដើម ។ ក្នុងបទនោះ បទថា **កិមស្ស** ប្រែថា នឹងគប្បីមានអ្វីហ្ន៎ ។

បទថា **យតំ ចរេ** សេចក្ដីថា ភិក្ខុគប្បីដើរសង្រួម ប្រុងប្រយ័ត្នក្នុងបទទាំងពួង ក៏ន័យនេះ ។

បទថា **អច្ឆេ** ប្រែថា គប្បីអង្គុយ ។

បទថា **តយមេតំ បសារយេ** សេចក្ដីថា គប្បីតម្រេតអវយវៈតូចធំសង្រួមគឺ រៀបរយ ។

បទថា **ឧទ្ធំ** ប្រែថា ខាងលើ ។

បទថា **តិរិយំ** ប្រែថា ខាងកណ្ដាល (ទទឹង)។

បទថា **អបាចីនំ** ប្រែថា ខាងក្រោម ។ បញ្ចខន្ធ ទាំងអតីត បច្ចុប្បន្ន និងអនាគត ត្រាស់ដោយហេតុប្រមាណប៉ុណ្ណេះ ។ ពាក្យថា **យាវតា** ជាពាក្យដែលសម្ដែងសេចក្ដីកំណត់ ។

បទថា **ជគតោ គតិ** បានដល់ សេចក្ដីសម្រេចនៃលោក ។

បទថា **សមវេក្ខិតា ច ធម្មានំខន្ធានំ ឧទយព្វយំ** សេចក្ដីថា ពិចារណាមើលការកើតឡើង សេចក្ដីសាបសូន្យទៅនៃធម៌ គឺបញ្ចខន្ធ ដែលផ្សេងដោយអតីតជាដើមទាំងនោះ ក្នុងលោកទាំងពួង គឺបានពិចារណាឃើញដោយប្រពៃដោយលក្ខណៈ ៥០ គត់ដែលលោកពោលថា កាលឃើញ ការកើតនៃបញ្ចខន្ធក៏

ពិចារណាឃើញលក្ខណៈ ២៥ បាន ។ កាលឃើញសេចក្ដីសាបសូន្យក៏ពិចារណាឃើញលក្ខណៈ ២៥ បាន ។

បទថា **ចេតោសមថស្វាមីចឹ** បានដល់ ខបដិបត្តិដែលសមគួរ ដល់សេចក្ដីស្ងប់ចិត្ត ។

បទថា **សិក្ខមានំ** សេចក្ដីថា កាលបដិបត្តិ គឺបំពេញ ។

បទថា **បហិតត្តោ** បានដល់ មានចិត្តក្តិច ។

បទថា **អាហុ** ប្រែថា ពោលនៅ ។ បទដ៏នៅសល់ក្នុងសូត្រនេះងាយទាំងនោះ ។ ក៏ក្នុងសូត្រនេះត្រាស់លាយគ្នានឹងសីលក្នុងគាថា ត្រាស់ដល់ភិក្ខុជាព្រះខីណាស្រព ។

## បឋមធម្មវិហារកសូត្រ

នៅក្នុងព្រះត្រៃបិដកលេខ ៤៤ទំព័រ ១៧៨ ព្រះអង្គទ្រង់ត្រាស់នូវបុគ្គលអ្នកតាំងនៅក្នុងធម៌ មានសេចក្ដីថា៖

គ្រានោះ ភិក្ខុមួយរូបចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីសមគួរហើយទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន គេតែងនិយាយថា **ភិក្ខុមានប្រក្រតីនៅដោយធម៌** ភិក្ខុមានប្រក្រតីនៅដោយធម៌ដូច្នេះ បពិត្រព្រះអង្គដ៏ចំរើន ចុះភិក្ខុមានប្រក្រតីនៅដោយធម៌ ដោយហេតុប៉ុន្មានយ៉ាង ។

ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ រៀននូវធម៌គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភុតធម្មៈ វេទល្លៈ ។ ភិក្ខុនោះញុំាងថ្ងៃឱ្យកន្លងទៅដោយការរៀននូវធម៌នោះ លះបង់នូវការសម្ងំនៅក្នុងទីស្ងាត់ មិនបានប្រកបរឿយៗនូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។ ភិក្ខុនេះហៅថា ជាអ្នកច្រើនដោយបរិយត្តិធម៌ មិនហៅថា ជាអ្នកមានប្រក្រតីនៅដោយធម៌ទេ ។

មួយទៀត ភិក្ខុសម្តែងធម៌តាមទំនងដែលខ្លួនបានចេះដឹងមក តាមទំនងដែលខ្លួនបានរៀនមក ដល់បុគ្គលទាំងឡាយដទៃដោយសេចក្តីពិស្តារ ភិក្ខុញុំាងថ្ងៃឱ្យកន្លងទៅដោយការបញ្ញត្តិនូវធម៌នោះ លះបង់នៅការសម្ងំនៅក្នុងទីស្ងាត់ មិនបានប្រកបរឿយៗ នូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។ ភិក្ខុនេះហៅថា ជាអ្នកច្រើនដោយបញ្ញត្តិ មិនហៅថា ជាអ្នកនៅដោយធម៌ទេ ។

មួយទៀត ភិក្ខុធ្វើនូវការស្វាធ្យាយនូវធម៌តាមទំនងដែលខ្លួនបានចេះដឹងមក តាមទំនងដែលខ្លួនបានរៀនមក ដោយសេចក្តីពិស្តារ ។ ភិក្ខុនោះញុំាងថ្ងៃឱ្យកន្លងទៅ ដោយការស្វាធ្យាយនោះ លះបង់នៅការសម្ងំនៅក្នុងទីស្ងាត់មិនបាន ប្រក្រតីរឿយៗនូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។ ភិក្ខុនេះហៅថា ជាអ្នកច្រើនដោយការស្វាធ្យាយ មិនហៅថា ជាអ្នកនៅដោយធម៌ទេ ។

មួយទៀត ភិក្ខុត្រិះរិះពិចារណាដោយចិត្ត ជញ្ជឹងដោយចិត្ត ចំពោះធម៌តាមទំនងដែលខ្លួនបានចេះដឹងមក តាមទំនងដែលខ្លួនបានរៀនមក ។ ភិក្ខុនោះញ៉ាំងថ្ងៃឱ្យកន្លងទៅ ដោយការត្រិះរិះនូវធម៌ទាំងនោះ លះបង់នៅការសម្ងំនៅក្នុងទីស្ងាត់ មិនបានប្រកបរឿយៗនូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។ ភិក្ខុនេះហៅថា ជាអ្នកច្រើនដោយសេចក្ដីត្រិះរិះនូវធម៌ មិនហៅថា ជាអ្នកនៅដោយធម៌ទេ ។

ភិក្ខុក្នុងសាសនានេះ រៀននូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភុតធម្មៈ វេទល្លៈ ។ ភិក្ខុនោះ មិនបានញ៉ាំងថ្ងៃឱ្យកន្លងទៅ ដោយការរៀននូវធម៌នោះ មិនលះបង់នូវការសម្ងំនៅក្នុងទីស្ងាត់ មិនបានប្រកបរឿយៗនូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។ ភិក្ខុនោះជាអ្នកនៅដោយធម៌យ៉ាងនេះឯង ។ ភិក្ខុជាអ្នកច្រើនដោយការរៀន តថាគតបានសម្ដែងហើយ អ្នកច្រើនដោយការបញ្ញត្តិ តថាគតបានសម្ដែងហើយ អ្នកច្រើនដោយស្វាធ្យាយ តថាគតបានសម្ដែងហើយ អ្នកមានប្រក្រតីនៅដោយធម៌ តថាគតបានសម្ដែងហើយដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុ អំពើណាដែលសាស្ដា ជាអ្នកស្វែងរកនូវប្រយោជន៍ ជាអ្នកអនុគ្រោះ អាស្រ័យនូវសេចក្ដីអនុគ្រោះ គួរធ្វើដល់សាវ័កទាំងឡាយ អំពើនោះតថាគតក៏បានធ្វើហើយដល់អ្នកទាំងឡាយ ។ ម្នាលភិក្ខុ ទីនោះជារុក្ខមូលសេនាសនៈ

ទីនោះជាជាសុញ្ញាគារសេនាសនៈ ។ អ្នកទាំងឡាយចូរចំរើន(នូវសមថៈនិងវិបស្សនា) អ្នកទាំងឡាយចូរកុំប្រមាទ អ្នកទាំងឡាយចូរកុំមានសេចក្ដីក្ដៅក្រហាយ[១] ក្នុងកាលជាខាងក្រោយឡើយ នេះជាពាក្យប្រៀនប្រដៅរបស់តថាគត ដល់អ្នកទាំងឡាយ ។

## បឋមអនាគតសូត្រ

នៅក្នុងព្រះត្រៃបិដកលេខ ៤៤ ទំព័រ ២០៩ ព្រះអង្គទ្រង់ត្រាស់នូវភ័យក្នុងអនាគត ៥ ប្រការ មានសេចក្ដីថាៈ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅក្នុងព្រៃកាលពិចារណាឃើញនូវអនាគតភ័យ ៥ យ៉ាងនេះ ជាអ្នកមិនប្រមាទ មានព្យាយាមញ៉ាំងកិលេសឱ្យក្ដៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឱ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់ធ្វើឱ្យជាក់ច្បាស់ ។ ភ័យ ៥ យ៉ាង តើដូចម្ដេចខ្លះ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកនៅព្រៃ

---

១-កាលពីដើមខ្លួននៅក្មេង ពុំទាន់មានរោគមកបៀតបៀន ច្រើនតែសប្បាយក្អេងក្អាងខ្លួនដោយការស៊ីផឹក ទោះបានជួបនឹងព្រះសាស្ដាជាម្ចាស់ ក៏មិនបានយកចិត្តទុកដាក់ ចូលចិត្តតែខាងដេកទាំងយប់ទាំងថ្ងៃឱ្យសង្កើចខាំឥតអំពើ ច្រើនធ្វេសប្រហែស(ឥតបាននឹកនាត្រង់ការកុសលណាសោះ) លុះវេលាខាងក្រោយមក ខ្លួនមានវ័យកាន់តែថយទៅៗចាស់ជរាគ្រាំគ្រា ទាំងរោគក៏មករួបរឹតរាងកាយ ទើបបាននឹកក្ដៅក្រហាយ ស្ដាយក្រោយ ។ អដ្ឋកថា ។

ពិចារណាឃើញដូច្នេះថា ឥឡូវនេះ អាត្មាអញនៅក្នុងព្រៃតែម្នាក់ឯង ពស់គប្បីចឹកអាត្មាអញក្តី ខ្ទួយគប្បីទិចអាត្មាអញក្តី ក្អែបគប្បីខាំអាត្មាអញក្តី ដែលនៅក្នុងព្រៃតែម្នាក់ឯង កាលកិរិយាគប្បីមានដល់អាត្មាអញ ដោយហេតុនោះ អន្តរាយនោះគប្បីមានដល់អាត្មាអញមិនខាន ។ បើដូច្នោះអាត្មាអញប្រារព្ធនូវសេចក្តីព្យាយាមដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឱ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់ធ្វើឱ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃកាលបើពិចារណាឃើញនូវអនាគតទី ១ នេះហើយ ជាអ្នកមិនប្រមាទ មានព្យាយាមញ៉ាំងកិលេសឱ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដល់នូវគុណវិសេសដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បានដើម្បីធ្វើឱ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឱ្យជាក់ច្បាស់ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកនៅព្រៃពិចារណាឃើញដូច្នេះថា ឥឡូវនេះ អាត្មាអញនៅក្នុងព្រៃតែម្នាក់ឯង គប្បីភ្ញាត់ដួលទៅក្តី ភត្តដែលអាត្មាអញបរិភោគហើយក្តី គប្បីឱ្យទោសក្តី ប្រមាត់របស់អាត្មាអញគប្បីកំរើកឡើងក្តី ស្លេស្មរបស់អាត្មាអញគប្បីកគ្រើកឡើងក្តី ខ្យល់ទាំងឡាយដែលមានមុខមុតដូចជាកាំបិត គប្បីកគ្រើកឡើងក្តី កាលកិរិយាគប្បីមានដល់អាត្មាអញដោយហេតុនោះ សេចក្តី

អន្តរាយនោះ គប្បីមានដល់អាត្មាអញមិនខាន ។ បើដូច្នោះ អាត្មាអញប្រារព្ធនូវសេចក្តីព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដើម្បីធ្វើឱ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់ធ្វើឱ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃ កាលបើពិចារណាឃើញនូវអនាគតទី ២ នេះហើយ ជាអ្នកមិនប្រមាទ មានព្យាយាមញ៉ាំងកិលេសឱ្យក្តៅ មានចិត្តបពាន្ធទៅកាន់ព្រះនិព្វាន ទើបអាចដល់នូវគុណវិសេសដែលខ្លួនមិនទានបានដល់ ដើម្បីបាននូវគុណវិសេសដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឱ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឱ្យជាក់ច្បាស់ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកនៅព្រៃពិចារណាឃើញដូច្នេះថា ឥឡូវនេះ អាត្មាអញនៅក្នុងព្រៃតែម្នាក់ឯង គប្បីជួបប្រទះនឹងម្រឹគសាហាវទាំងឡាយគឺរាជសីហ៍ក្តី ខ្លាធំក្តី ខ្លាដម្បងក្តី ខ្លាឃ្មុំក្តី ខ្លាត្រីក្តី ម្រឹគសាហាវទាំងនោះ គប្បីផ្តាច់បង់អាត្មាអញចាកជីវិត កាលកិរិយាគប្បីមានដល់អាត្មាអញ ដោយហេតុនោះ សេចក្តីអន្តរាយនោះ គប្បីមានដល់អាត្មាអញមិនខាន ។ បើដូច្នោះ អាត្មាអញប្រារព្ធនូវសេចក្តីព្យាយាមដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីដល់នូវគុណវិសេសដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឱ្យជាក់

ច្បាស់នូវគុណវិសេសដែលខ្លួនមិនទាន់ធ្វើឱ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃកាលបើពិចារណាឃើញនូវអនាគតទី ៣ នេះហើយ ជាអ្នកមិនប្រមាទ មានព្យាយាមញុំាងកិលេសឱ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដល់នូវគុណវិសេសដែលខ្លួនមិនទាន់បានដល់ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឱ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឱ្យជាក់ច្បាស់ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកនៅព្រៃពិចារណាឃើញដូច្នេះថា ឥឡូវនេះ អាត្មាអញនៅក្នុងព្រៃតែម្នាក់ឯង គប្បីជួបប្រទះនឹងពួកចោរដែលធ្វើចោរកម្មហើយក្តី ដែលមិនទាន់បានធ្វើចោរកម្មក្តី ចោរទាំងនោះគប្បីផ្តាច់បង់នូវអាត្មាអញចាកជីវិតទៅ កាលកិរិយាគប្បីមានដល់អាត្មាអញ ដោយហេតុនោះ សេចក្តីអន្តរាយនោះ គប្បីមានដល់អាត្មាអញមិនខាន ។ បើដូច្នោះ អាត្មាអញប្រារព្ធនូវសេចក្តីព្យាយាម ដើម្បីដល់នូវគុណវិសេសដែលខ្លួនមិនទាន់បានដល់ ដើម្បីដល់នូវគុណវិសេសដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឱ្យជាក់ច្បាស់នូវគុណវិសេសដែលខ្លួនមិនទាន់ធ្វើឱ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃ កាលបើពិចារណាឃើញនូវអនាគតទី ៤ នេះហើយជាអ្នកមិនប្រមាទ មានព្យាយាមញុំាងកិលេសឱ្យក្តៅ

មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឱ្យជាក់ច្បាស់ ។

ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកនៅព្រៃពិចារណាឃើញដូច្នេះថា ឥឡូវនេះ អាត្មាអញនៅក្នុងព្រៃតែម្នាក់ឯង ប្រសិនបើមានអមនុស្សកំណាចនៅក្នុងព្រៃ អមនុស្សកំណាចទាំងនោះ គប្បីផ្ដាច់បង់នូវអាត្មាអញចាកជីវិតទៅ កាលកិរិយាគប្បីមានដល់អាត្មាអញដោយហេតុនោះ សេចក្ដីអន្តរាយនោះ គប្បីមានដល់អាត្មាអញមិនខាន ។ បើដូច្នោះ អាត្មាអញប្រារព្ធនូវសេចក្ដីព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីដល់នូវគុណវិសេសដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឱ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់ធ្វើឱ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃ កាលបើពិចារណាឃើញនូវអនាគតទី ៥ នេះហើយ ជាអ្នកមិនប្រមាទ មានព្យាយាមញ៉ាំងកិលេសឱ្យក្ដៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានទើបអាចដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឱ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឱ្យជាក់ច្បាស់ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃ កាលបើពិចារណាឃើញនូវអនាគតភ័យទាំង ៥ យ៉ាងនេះឯង ជាអ្នកមិនប្រមាទ មានព្យាយាមញ៉ាំងកិលេសឱ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឱ្យជាក់ច្បាស់ ។

## រឿងព្រះមហាមិត្តត្ថេរ

បានឮមកថា ព្រះថេរៈអាស្រ័យនៅក្នុងល្អាងឈ្មោះកសកៈ ។ និងមហាឧបាសិកាម្នាក់ក្នុងស្រុក ជាទីគោចររបស់លោក ទំនុកបម្រុងព្រះថេរៈដូចបុត្រ ។ ថ្ងៃមួយ នាងទៅព្រៃទើបប្រាប់កូនស្រីថា កូន ! ម្ហូបអង្ករនៅឯណោះ ទឹកដោះ ទឹកដោះថ្លា ទឹកអំពៅនៅឯណោះ វេលាដែលលោកម្ចាស់មិត្តៈ បងប្រុសរបស់កូនមកហើយ ចូរផ្សំអាហារថ្វាយ ព្រមដោយទឹកដោះ ទឹកដោះថ្លា និងទឹកអំពៅផងណាកូន ។ កូនស្រីសួរថា ក៏ម៉ែនឹងទទួលទានទេចាំ ។ មហាឧបាសិកាឆ្លើយថា កាលថ្ងៃម្សិលមិញម៉ែ ហូបអាហារដែលទុក ១ យប់ (បារិវាសកភត្ត) ដែលផ្សំនឹងទឹកដោះជូរ នោះហើយ ។ កូនស្រីសួរថា ម៉ែនឹងពិសារពេលថ្ងៃ ។ មហាឧបាសិកាប្រាប់ថា នាងចូរដាក់បន្លែជ្រក់ ហើយយកញ៉ុងអង្ករ បបរ មានរសជូរ ទុកឱ្យម៉ែចុះ ។ ព្រះថេរៈគ្រងចីវរ ហើយ

កំពុងនាំបាត្រចេញ(ពីស្ពាក) បានឮសំឡេងនោះហើយ ក៏ទូន្មាន ខ្លួនឯងថា បានឮថា មហាឧបាសិកា ហូបតែអាហារដែលទុក ១ យប់ និងទឹកដោះជូរ សូម្បីពេលថ្ងៃ ក៏នឹងទទួលទានបបរជូរ ដាក់ បន្លែជ្រក់ នាងប្រាប់អាហារមានបាយជាដើម ដើម្បីប្រយោជន៍ ដល់លោក ក៏មហាឧបាសិកានោះ មិនបានប្រាថ្នាទីស្រែ ទីសួន អាហារ និងសម្លត់ ព្រោះអាស្រ័យលោកឡើយ តែប្រាថ្នាសម្បត្តិ ៣ ប្រការ (មនុស្សសម្បត្តិ សួគ៌សម្បត្តិ និព្វានសម្បត្តិ) ទើប ប្រគេនលោកនឹងអាចឱ្យសម្បត្តិទាំងនោះ ដល់មហាឧបាសិកា នោះបានឬទេហ្ន៎ ដូច្នេះ លោកគិតថា បិណ្ឌបាតនេះឯង យើង នៅមានរាគៈ ទោសៈ មោហៈ នៅមិនអាចទទួលបានដូច្នេះហើយ ក៏ទុកបាត្រក្នុងស្ពាក ដោះក្តុំចីវរ ត្រឡប់ទៅល្អាងកសកៈ រក្សា បាត្រទុកក្រោមគ្រែ ពាក់ចីវរទុកត្រង់ស្នួរចីវរ អង្គុយចុះ អធិដ្ឋាន សេចក្តីព្យាយាមថា បើយើងមិនសម្រេចព្រះអរហត្តនិងមិនចេញ ទៅពីល្អាងដូច្នេះៗភិក្ខុដែលមិនប្រមាទមកអស់កាលជាយូរអង្វែង ហើយ ចម្រើនវិបស្សនា ក៏សម្រេចព្រះអរហត្តមុន វេលាអាហារ ព្រឹកជាព្រះមហាខីណាស្រព (អស់អាសវៈហើយ) អង្គុយញញឹម ដូចផ្កាបទុមដែលកំពុងរីកដូច្នោះ ។ ទេវតាស្ថិតនៅដើមឈើជិត ទ្វារល្អាងបន្លឺឧទានថា៖

ឯមោ តេ បុរិសាជញ្ញ ឯមោ តេ បុរិសុត្តម

**យស្ស តេ អាសវា ខីណា ទក្ខិណេយ្យោសិ មារិស**

លោកជាបុរសអាជានេយ្យ ខ្ញុំសូមមនស្ការលោក លោកជាកំពូលបុរស ខ្ញុំសូមនមស្ការលោក ខ្ញុំសូមនមស្ការលោក អ្នកមានអាសវៈអស់ហើយ លោកអ្នកនិរទុក្ខ លោកជាអ្នកគួរដល់ទក្ខិណាទាន ដូច្នេះ ។

ហើយពោលថា លោកម្ចាស់ ពួកស្ត្រីថ្វាយអាហារដល់ព្រះអរហន្តទាំងឡាយ ដូចលោកម្ចាស់អ្នកចូលទៅបិណ្ឌបាត នឹងផុតពីទុក្ខបានដូច្នេះ ។

ព្រះថេរៈក្រោកឡើង បើកទ្វារមើលវេលាជ្រាបថា នៅព្រឹកទើបកាន់បាត្រ និងចីវរចូលកាន់ស្រុក ចំណែកក្មេងស្រីត្រៀមអាហារសម្រេចហើយ អង្គុយចាំមើលនៅត្រង់ទ្វារដោយនឹកថាបន្តិចទៀតបងប្រុសយើងគង់នឹងមក បន្តិចទៀតបងប្រុសយើងគង់នឹងមក ។ កាលព្រះថេរៈមកដល់ទ្វារផ្ទះហើយ ក្មេងស្រីនោះក៏ទទួលបាត្រដាក់ពេញដោយអាហារ លាយទឹកដោះ ដែលផ្សំដោយទឹកដោះថ្លា និងទឹកអំពៅហើយ ដាក់លើដៃ(របស់ព្រះថេរៈ)។ ព្រះថេរៈធ្វើអនុមោទនាថា ចូរបានសុខចុះ ហើយក៏ចៀសចេញទៅ ។ ក្មេងស្រីនោះឈរសម្លឹងមើលលោកហើយ ។ សេចក្តីពិតក្នុងគ្រានោះ ពណ៌សម្បុររបស់ព្រះថេរៈ បរិសុទ្ធិក្រៃលែងណាស់ ឥន្ទ្រិយថ្លាផូរផង់ មុខរបស់លោកស្រស់បស់ក្រៃលែង ដូចផ្លែត្នោតទុំជ្រុះចាកទង ដូច្នោះ ។ មហាឧបាសិកា ត្រឡប់មកពី

ព្រៃ សួរថា បងប្រុស របស់នាងមកហើយឬកូន ។ ក្មេងស្រីនោះ ក៏ប្រាប់រឿងទាំងអស់ឱ្យមាតាស្តាប់ ។ មហាឧបាសិកាក៏ដឹងបានថា ថ្ងៃនេះ កិច្ចបព្វជិតនៃបុត្ររបស់យើងដល់ទីបំផុតហើយ ទើបពោលថា កូន ! បងប្រុសរបស់កូន ត្រេកអរក្រៃលែងណាស់ក្នុងព្រះពុទ្ធសាសនា មិនអផ្សុក(ចង់សឹក)ឡើយដូច្នេះ ។

## វិត្ថារសូត្រ

នៅក្នុងព្រះត្រៃបិដកលេខ ៤៣ ទំព័រ ២២ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សម្តែងជាមួយភិក្ខុទាំងឡាយអំពី បដិបទា ៤ យ៉ាង សេចក្តីថា៖

ម្នាលភិក្ខុទាំងឡាយ បដិបទានេះមាន ៤ ។ បដិបទា ៤ គឺអ្វីខ្លះ ។

**១- ទុក្ខា បដិបទា ទន្ធាភិញ្ញា** គឺប្រតិបត្តិលំបាក ទាំងត្រាស់ដឹងដ៏យឺតយូរ ១

**២- ទុក្ខា បដិបទា ខិប្បាភិញ្ញា** ប្រតិបត្តិលំបាក តែត្រាស់ដឹងឆាប់ ១

**៣- សុខា បដិបទា ទន្ធាភិញ្ញា** ប្រតិបត្តិស្រួល តែត្រាស់ដឹងយឺតយូរ

**៤- សុខា បដិបទា ខិប្បាភិញ្ញា** ប្រតិបត្តិស្រួល ទាំងត្រាស់ដឹងក៏ឆាប់ ។

ម្នាលភិក្ខុ**ទាំងឡាយ ចុះប្រតិបត្តិលំបាក ទាំងត្រាស់ដឹងដ៏យឺតយូរ** តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណាឃើញគ្រឿងមិនស្អាតក្នុងកាយ កំណត់សេចក្តីបដិកូលក្នុងអាហារ កំណត់សេចក្តីមិនត្រេកអរក្នុងលោកទាំងពួង ឃើញនូវសេចក្តីមិនទៀងក្នុងសង្ខារទាំងពួង មួយទៀត ភិក្ខុនោះកំណត់សេចក្តីស្លាប់ ដម្កល់ទុកដោយប្រពៃល្អដ៏ខាងក្នុង ។ ភិក្ខុនោះ តែងអាស្រ័យសេក្ខពល(ធម៌ជាកម្លាំងរបស់ព្រះសេក្ខៈ ៥ នេះគឺ សទ្ធាពល ហិរិពល ឱត្តប្បពល វិរិយពល បញ្ញាពល ឥន្ទ្រិយទាំង ៥ នេះគឺសទ្ធិន្ទ្រិយ វិរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ នៅទន់ខ្សោយ រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះតែឥន្ទ្រិយទាំង ៥ នេះនៅទន់ខ្សោយដែរ ភិក្ខុនោះក៏សម្រេចអនន្តរិយគុណ ដើម្បីអស់អាសវៈទាំងឡាយ បានយឺតយូរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **គឺប្រតិបត្តិលំបាក ទាំងត្រាស់ដឹងដ៏យឺតយូរ ។**

ម្នាលភិក្ខុទាំងឡាយ **ចុះប្រតិបត្តិលំបាក ទាំងត្រាច់ដឹងឆាប់** តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណាឃើញគ្រឿងមិនស្អាតក្នុងកាយ កំណត់សេចក្តីបដិកូលក្នុងអាហារកំណត់សេចក្តីមិនត្រេកអរក្នុងលោកទាំងពួង ឃើញនូវសេចក្តីមិនទៀងក្នុងសង្ខារទាំងពួង មួយទៀត ភិក្ខុនោះកំណត់

សេចក្តីស្លាប់ ដម្កល់ទុកដោយប្រពៃពេញដ៏ខាងក្នុង ។ ភិក្ខុនោះតែង អាស្រ័យសេក្ខពល(ធម៌ជាកម្លាំងរបស់ព្រះសេក្ខៈ) ៥ នេះគឺ សទ្ធា-ពល ហិរិពល ឱត្តប្បពល វីរិយពល បញ្ញាពល ឥន្ទ្រិយទាំង ៥ នេះគឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ក្លៀវក្លា រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះតែឥន្ទ្រិយទាំង ៥ នេះ ក្លៀវក្លាដែរ ភិក្ខុនោះក៏សម្រេចអនន្តរិយគុណដើម្បីអស់ អាសវៈទាំងឡាយបានឆាប់ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា គឺ **ប្រតិបត្តិលំបាក តែត្រាច់ដឹងឆាប់ ។**

ម្នាលភិក្ខុទាំងឡាយ **ចុះប្រតិបត្តិស្រួល តែត្រាស់ដឹងយឺតយូរ** តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលទាំងឡាយ បាន ដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈ និងវិចារៈ មានបីតិ និង សុខៈ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់នោះ ភិក្ខុនោះ ព្រោះស្ងប់ ស្ងាត់ចាកវិតក្កៈនិងវិចារៈ ក៏បានដល់នូវទុតិយជ្ឈាន ជាធម្មជាត កើតក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លា គឺសទ្ធា មាន សភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មានតែបីតិនិងសុខៈ ដែល កើតអំពីសមាធិ គឺបឋមជ្ឈាន ភិក្ខុ ព្រោះនឿយណាយចាកបីតិ ផង ប្រកបដោយឧបេក្ខាផង មានស្មារតីដឹងខ្លួនដោយប្រពៃផង ទទួលសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយតែងសរសើរ

នូវបុគ្គលដែលបាននូវតតិយជ្ឈាននោះថា បុគ្គលនោះប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានឯណា ក៏បានដល់នូវតតិយជ្ឈាននោះ ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង ព្រោះអស់ទៅនៃសោមនស្ស និងទោមនស្សក្នុងកាលមុន ក៏បានដល់នូវចតុត្ថជ្ឈាន ជាធម្មជាតមានអារម្មណ៍មិនមែនជាទុក្ខ មិនមែនជាសុខ គឺជាឧបេក្ខា មានសតិដ៏បរិសុទ្ធិដោយឧបេក្ខា ។ ភិក្ខុនោះតែងអាស្រ័យនូវសេក្ខ-ពល ៥ នេះ គឺសទ្ធាពល ហិរិពល ឱត្តប្បពល វីរិយពល បញ្ញា-ពល ឥន្ទ្រិយទាំង ៥ នេះ គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ជាធម្មជាតទន់ខ្សោយ រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះតែឥន្ទ្រិយទាំង ៥ នេះ នៅទន់ខ្សោយដែរ ភិក្ខុនោះក៏សម្រេចអនន្តរិយគុណ ដើម្បីអស់អាសវៈទាំងឡាយបានយឺតយូរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **គឺប្រតិបត្តិស្រួលតែត្រាស់ដឹងយឺតយូរ ។**

ម្នាលភិក្ខុទាំងឡាយ ចុះ**ប្រតិបត្តិស្រួល ទាំងត្រាស់ដឹងក៏បានឆាប់** តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះស្ងាត់ចាកកាមទាំងឡាយ (ស្ងាត់ចាកអកុសលទាំងឡាយ បាននូវបឋមជ្ឈាន ប្រកបដោយវិតក្កៈនិងវិចារៈ(មានបីតិនិងសុខៈ ដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់នោះ ភិក្ខុនោះ ព្រោះស្ងប់ស្ងាត់ចាក

វិតក្កៈនិងវិចារៈ) ក៏ដល់នូវទុតិយជ្ឈាន ជាធម្មជាតកើតក្នុងសន្ដាននៃខ្លួន ប្រកបដោយសេចក្ដីជ្រះថ្លាគឺ សទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មានតែបីតិនិងសុខៈដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ភិក្ខុ ព្រោះនឿយណាយចាកបីតិផង ប្រកបដោយឧបេក្ខាផង មានស្មារតីដឹងខ្លួនដោយប្រពៃផង ទទួលសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយ តែងសរសើរនូវបុគ្គលដែលបាននូវតតិយជ្ឈាននោះថា បុគ្គលនោះប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានឯណា ក៏ដល់នូវតតិយជ្ឈាននោះ ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង ព្រោះអស់ទៅនៃសោមនស្ស និងទោមនស្សក្នុងកាលមុន ក៏ដល់នូវចតុជាធម្មជាតមានអារម្មណ៍មិនមែនជា ទុក្ខមិនមែនជាសុខ គឺជាឧបេក្ខា មានសតិដ៏បរិសុទ្ធិដោយឧបេក្ខា ។ ភិក្ខុនោះអាស្រ័យនូវសេក្ខពល ៥ នេះ គឺសទ្ធាពល ហិរិពល ឱត្តប្បពល វីរិយពល បញ្ញាពល ឥន្ទ្រិយទាំង ៥ នេះ គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយក្លៀវក្លា រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះតែឥន្ទ្រិយទាំង ៥ នេះ ក្លៀវក្លាដែរ ភិក្ខុនោះក៏សម្រេចអនន្តរិយគុណ ដើម្បីអស់អាសវៈទាំងឡាយបានយឺតយូរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **គឺប្រតិបត្តិស្រួល តែត្រាស់ដឹងក៏បានឆាប់ ។**

# បឋមសេក្ខសូត្រ

នៅក្នុងព្រះត្រៃបិដកលេខ ៤៤ ទំព័រ ២៤០ ព្រះអង្គទ្រង់ត្រាស់នូវធម៌ **ប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យ និងមិនសាបសូន្យរបស់ព្រះសេក្ខ** មានសេចក្តីថា:

ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។

**១-កម្មារាមតា** គឺសេចក្តីត្រេកអរនឹងការងារ

**២-ភស្សារាមតា** សេចក្តីត្រេកអរនឹងតិរច្ឆានកថា

**៣-និទ្ទារាមតា** សេចក្តីត្រេកអរនឹងការដេក

**៤-សង្គណិការាមតា** សេចក្តីត្រេកអរនឹងការប្រឡូកប្រឡំដោយពួក

**៥-យថាវិមុត្តំ ចិត្តំ ន បច្ចវេក្ខតិ** មិនពិចារណាចិត្តដែលផុត (ចាកកិលេស)យ៉ាងណា។

ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។

## ធម៌ប្រព្រឹត្តទៅដើម្បីសេចក្តីមិនសាបសូន្យនៃព្រះសេក្ខៈ

ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ។

**១-ន កម្មារាមតា** គឺសេចក្តីមិនត្រេកអរនឹងការងារ

**២-ន ភស្សារាមតា** សេចក្តីមិនត្រេកអរនឹងតិរច្ឆានកថា

**៣-ន និទ្ទារាមតា** សេចក្តីមិនត្រេកអរនឹងការដេក

**៤-ន សង្គណិការាមតា** សេចក្តីមិនត្រេកអរនឹងការច្រឡូកច្រឡំដោយពួក

**៥-ន យថាវិមុត្តំ ចិត្តំ ន បច្ចវេក្ខតិ** មិនពិចារណាចិត្តដែលផុត(ចាកកិលេស)យ៉ាងណា។

ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ប្រព្រឹត្តទៅដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុជាសេក្ខៈ។

## អដ្ឋកថា

បទថា **សេក្ខស្ស** បានដល់ ភិក្ខុអ្នកនៅមានការសិក្សា គឺនៅមានកិច្ចដែលត្រូវធ្វើ ។

បទថា **បរិហានាយ** បានដល់ ដើម្បីសាបសូន្យចាកគុណយ៉ាងខ្ពង់ខ្ពស់ ។

សេចក្តីត្រេកអរក្នុងនវកម្ម ការបង្កសាងសង់ ឈ្មោះថា **កម្មារាមតា** ។

សេចក្តីត្រេកអរក្នុងការសន្ទនាប្រាស្រ័យ (ជាមួយគ្នា)ឱ្យឈ្មោះថា **ភស្សារាមតា** ។

សេចក្តីត្រេកអរក្នុងការដេកលក់ ឈ្មោះថា **និទ្ទារាមតា** ។

សេចក្តីត្រេកអរនៅក្នុងភាពច្រឡូកច្រឡំគ្នាជាពួក ឈ្មោះ

ថា **សង្គណិការាមតា** ។

បទថា **យថាវិមុត្តំ ចិត្តំ ន បច្ចវេក្ខតិ** សេចក្តីថា មិនបាន ពិចារណាចិត្តដែលផុតស្រឡះហើយ ពិចារណានូវទោសដែលខ្លួនលះបាន និងគុណដែលខ្លួនបានទាំងនោះហើយ រមែងមិនធ្វើសេចក្តីព្យាយាមដើម្បីបានគុណយ៉ាងខ្ពស់តទៅទៀត ។ ក្នុងសូត្រនេះ ត្រាស់ហេតុនៃសេចក្តីសាបសូន្យនិងហេតុនៃសេចក្តីចំរើន ដោយគុណយ៉ាងខ្ពស់របស់ព្រះសេក្ខ ៧ ពួក ដោយប្រការយ៉ាងនេះ ។ ក៏សេចក្តីណាជាហេតុនៃសេចក្តីសាបសូន្យរបស់ព្រះសេក្ខៈ សេចក្តីនោះមានន័យដូចបុថុជ្ជនដែរ ដោយប្រការដូច្នេះ ។

## លក្ខណៈជាដើមរបស់ភាវនាកុសល

**១-កុសលវឌ្ឍាបនលក្ខណា** មានការធ្វើឱ្យកុសលចម្រើនឡើង ជាលក្ខណៈ

**២-អកុសលបហានរសា** មានការលះបង់អកុសល ជាកិច្ច

**៣-សត្តាចាពោក្កមនបច្ចុប្បដ្ឋានា** មានការចូលកាន់ផ្លូវបដិបត្តិដែលទាក់ទងជាមួយសតិរបស់នាមកាយ រូបកាយ ជាអាការប្រាកដ

**៤-យោនិសោមនសិការបទដ្ឋានា** មានយោនិសោមនសិការ គឺការពិចារណាដោយឧបាយជាហេតុជិត ។

## បដិក្ខេបធម៌ជាដើមរបស់ភាវនាកុសល

**១-បដិក្ខេបធម្ម** ធម៌ដែលត្រូវលះបង់ដោយភាវនា បានដល់មោហៈ

**២-អនុញ្ញាតធម្ម** ធម៌ដែលបានទទួលអនុញ្ញាតអំពីភាវនាកុសលឱ្យកើត បានដល់ អមោហៈ

**៣-ឧប្បាទេតព្វធម្ម** ធម៌ដែលភាវនាកុសល ធ្វើឱ្យកើតឡើង បានដល់ អរហត្តមគ្គ អហរត្តផល (ដោយឧក្កដ្ឋន័យ)។

## អប់រំចិត្ត

-ចិត្តវិវេក ចិត្តស្ងប់ ចិត្តស្អាត ចិត្តបរិសុទ្ធ

-ចិត្តសូន្យប្រកាន់ សូន្យកង្វល់

-ចិត្តសូន្យនិមិត្ត សូន្យជំពាក់

-ចិត្តសូន្យកិលេស ⇨សូន្យសៅហ្មងគឺរស់នៅស្រាលៗគ្មានទម្ងន់ រស់នៅធូរៗគ្មានចំណងរួបរឹត

-មានសីលបរិសុទ្ធ ⇨ ជាទីពឹង

-មានវិបស្សនាបញ្ញា ⇨ ជាទីរលឹក

-មានទិដ្ឋិវិមុត្តិ ជាទីបង្អែក។

បុណ្យបានមកដោយសារការទូន្មានអប់រំ អត់ធ្មត់ សង្កត់ចិត្តឱ្យស្ងប់ បានដល់ការចម្រើនសតិប្បដ្ឋាន សមាធិ វិបស្សនា ដើម្បីធ្វើឱ្យចិត្តឋិតនៅនឹងធឹង ស្ងប់រម្ងាប់ បរិសុទ្ធស្អាត ចាកបាប

អកុសល ពាល់ទង្វើអាក្រក់ផ្សេងៗ ដែលនាំឱ្យចិត្តកករល្អក់ សៅហ្មង ឯទង្វើអាក្រក់ដែលធ្វើឱ្យចិត្តមិនស្ងប់នោះមាន ៣ យ៉ាងគឺៈ

**១- អភិជ្ឈា** គិតសំឡឹងរំពៃ លួច ឆក់ ប្លន់ ចង់បានទ្រព្យសម្បត្តិអ្នកដទៃ ។

**២- ព្យាបាទ** ការខឹងក្រោធ ច្រណែនឈ្នានីស គំនុំគុំគួន ចង់អាឃាត ព្យាបាទអ្នកដទៃ ។

**៣- មិច្ឆាទិដ្ឋិ** ការយល់ខុសចាកពីហេតុផលពិត ជាក់ស្ដែង ដូចយល់ឃើញថា ឪពុកម្ដាយមិនមានគុណ គ្មានបុណ្យ គ្មានបាប គ្មានជាតិមុន គ្មានជាតិក្រោយ ជាដើម ។

**ការអប់រំទូន្មានគ្រប់សង្កត់ចិត្តនេះ** គឺសំខាន់ខ្លាំងណាស់ ដែលអាចធ្វើអ្វីផ្សេងៗ ឬពោលស្ដីនិយាយអ្វីបានក៏ដោយ សារចិត្ត ជាអ្នកបង្គាប់បញ្ជាមក ទើបធ្វើ ឬនិយាយស្ដីទៅកើត បើចិត្តគិតរឿង អាក្រក់ហើយ ទោះធ្វើទង្វើអ្វីក៏ដោយពោលនិយាយស្ដីអ្វីក៏ដោយ ក៏សុទ្ធតែអាក្រក់ទៅតាមចិត្តនោះទាំងអស់អ៊ីចឹងដែរ តែបើចិត្តគិតរឿងល្អ រឿងបុណ្យកុសល ទោះធ្វើអ្វីក្ដី និយាយស្ដីអ្វីក្ដី ក៏សុទ្ធតែល្អ ជាបុណ្យកុសលទាំងអស់ដែរ ដូច្នេះត្រូវខំប្រឹងប្រែងព្យាយាមទូន្មាន អប់រំគ្រប់សង្កត់ចិត្ត គឺធ្វើឱ្យចិត្តគិតតែរឿងល្អៗតែម្យ៉ាងប៉ុណ្ណោះ មួយវិញទៀត ការអប់រំទូន្មាន គ្រប់សង្កត់ចិត្តនេះទៀតសោត ក៏ជាចំណុចសំខាន់បំផុត នៅក្នុងព្រះ

ពុទ្ធសាសនាផងដែរ ដែលអាចជួយឱ្យបានទៅដល់គោលដៅចុង ក្រោយ នោះគឺជាព្រះនិព្វាន ។

## សមាធិជួយឲ្យស្ងប់

-ស្ងប់ត្រេកអរនឹងរូប ស្ងប់លោភៈ

-ស្ងប់ក្រោធខឹងនឹងសម្លេង ស្ងប់ទោសៈ

-ស្ងប់ជាប់នឹងរស ស្ងប់រាគៈ

-ស្ងប់សប្បាយនឹងក្លិន ស្ងប់ជំពាក់

-ស្ងប់វង្វេងនឹងកាយសម្ផស្ស ស្ងប់ផោដ្ឋព្វៈ

-ស្ងប់ប្រកាន់ខ្លួន ស្ងប់មានះ

-ស្ងប់អញ លះរបស់អញ⇨ ស្ងប់ទិដ្ឋិ (ស្ងប់យល់ខុស)។

## ទន្តោ សេដ្ឋោ មនុស្សេសុ។

មនុស្សដែលល្អ គឺមនុស្សដែលចេះអប់រំទូន្មានខ្លួន ។

## ភាវនាមយៈ ចប់

# គម្ពីរជាឧបករណ៍ក្នុងការរៀបរៀងសៀវភៅនេះ

គម្ពីរព្រះត្រៃបិដករបស់ពុទ្ធសាសនបណ្ឌិត ព.ស. ២៥៥៧

អដ្ឋកថាពន្យល់សេចក្ដីនៃគម្ពីរព្រះត្រៃបិដក ព.ស. ២៥២២

គម្ពីរឃ្លាំងបរិយត្តិភាគ ១ ២ ព.ស. ២៥៤៧

គម្ពីរធម្មាវលី របស់ភិក្ខុ ធម្មវរាចារ្យ

គម្ពីរបរមត្ថជោតិកា បរិច្ឆេទទី ៥ ក្បាលទី ១ ព.ស. ២៥៤០

បុញ្ញកិរិយាវត្ថុ លោកគ្រូ ភួង សុវណ្ណ ព.ស. ២៥៥៥

វចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត ព.ស. ២៥១១

ព្រមទាំងឯកសាមួយចំនួនទៀត

# ព្រះពុទ្ធគាថា

**សំវរោ ច បហានញ្ច ភាវនា អនុរក្ខនា**
**ឯតេ បធានា ចត្តារោ ទេសិតាទិច្ចពន្ធុនា**
**យេហិ ភិក្ខុ ឥធាតាបី ខយំ ទុក្ខស្ស បាបុណេតិ ។**

*សំវរប្បធាន ១ បហានប្បធាន ១ ភាវនាបធាន ១ អនុរក្ខនាបធាន ១ បធានទាំង ៤ យ៉ាងនេះ ព្រះពុទ្ធជាផៅពង្សនៃព្រះអាទិត្យ ទ្រង់សម្តែងហើយ ដែលភិក្ខុក្នុងសាសនានេះមានព្យាយាមដុតកំដៅកិលេស បានដល់នូវអរហត្ត ជាធម៌អស់ទៅនៃទុក្ខ ។*